00340491

E72

001/១៨-០៧-២០០៧-អវតក/អជសដ

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 09 / JUN / 2009
ម៉ោង (Time/Heure): 13:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A.Tuy

| | | |
|---|---|---|
| សំណុំរឿងលេខ | : | 001/១៨-០៧-២០០៧-អវតក/អជសដ |
| កាលបរិច្ឆេទ | : | ខែមិថុនា ឆ្នាំ២០០៩ |
| ភាគីដាក់ជូនសារណា | : | មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្រុម១ និង ២ |
| ភាសាដើម | : | ភាសាអង់គ្លេស |
| ចំណាត់ថ្នាក់ឯកសារ | : | សាធារណៈ |

---

## ក្រុម ១ និង ២ --

## សំណើរួមរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំឲ្យចេញសេចក្តីសម្រេចលើសិទ្ធិរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការធ្វើសេចក្តីសន្និដ្ឋានអំពីការផ្តន្ទាទោស

***សាធារណៈ***

---

**<u>ដាក់ជូនដោយ</u>:**

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**

លោក Karim A.A. KHAN
កញ្ញា ទី ស្រីនណា
លោក Alain WERNER
លោកស្រី Brianne McGONIGLE
លោក គង់ ពិសី
លោក ហុង គឹមសួន
លោក យុង ផានិត
លោកស្រីSilke STUDZINSKY

**<u>ជូនចំពោះ</u>:**

**អង្គជំនុំជម្រះសាលាដំបូង:**

ចៅក្រម **និល ណុន** ជាប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម **យ៉ា សុខន**
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម **ធូ មណី**

**<u>ចម្លងជូន</u>:**

**ជនជាប់ចោទ:**

លោក កាំង ហ្គេក អ៊ាវ ហៅ "ឌុច"

**សហមេធាវីការពារក្តីជនជាប់ចោទ:**

លោក ការ សាវុត្ថ
លោក François ROUX

**ការិយាល័យសហព្រះរាជអាជ្ញា:**

លោកស្រី ជាលាង
លោក Robert PETIT
លោក យ៉េត ចរិយា

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 16 / 06 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A.Tuy

Original EN: 00333990-00334012

E72

០០១/១៨-០៧-២០០៧-អវតក/អជសង

លោក William SMITH

លោក ពេជ្រ សម្បត្តិ

លោក Alex BATES

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:**

លោក គឹម ម៉េងឃី

កញ្ញា ម៉ុច សុវណ្ណារី

លោកស្រី Martine JACQUIN

លោក Philippe CANONNE

លោក Pirre-Olivier SUR

**ជួយរៀបចំដោយ:**

លោកស្រី Daniella RUDY

លោកស្រី Kate GIBSON

លោក Patrick KROKER

# I. សេចក្តីផ្តើម

១. សហមេធាវីការពារក្តីបានលើកឡើងថា ដើមបណ្តឹងរដ្ឋប្បវេណី *"ពុំមានតួនាទីអ្វីត្រូវបំពេញ ពាក់ព័ន្ធនឹងការផ្តន្ទាទោសជនត្រូវចោទនោះទេ"*[1] និងបាននិយាយថា ខ្លួន *"នឹងជំទាស់ដាច់ខាតចំពោះការអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណី លើកជូនតុលាការពាក់ព័ន្ធនឹងបញ្ហានៃការផ្តន្ទាទោស"*[2]។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្រុម១ (CPG-1) និង ក្រុម២ (CPG-2) មានគោលជំហរស្របគ្នាថា ដើមបណ្តឹងរដ្ឋប្បវេណីមិនត្រឹមតែមានសិទ្ធិក្នុងការធ្វើសេចក្តីសន្និដ្ឋានស្តីពីការផ្តន្ទាទោសប៉ុណ្ណោះទេ ប៉ុន្តែជាសំខាន់ពួកគេថែមទាំងនឹងជួយអង្គជំនុំជម្រះក្នុងការផ្តន្ទាទោសទៀតផង[3]។ វិធានផ្ទៃក្នុងអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើសេចក្តីសន្និដ្ឋានស្តីពីការផ្តន្ទាទោសរីឯប្រតិបត្តិការជាអន្តរជាតិ និងក្នុងស្រុកដែលពាក់ព័ន្ធបានគាំទ្រជំហររបស់ CPG-1 និង CPG-2។

២. ហេតុនេះ CPG-1 និង CPG-2 ស្នើសុំការសម្រេចពីអង្គជំនុំជម្រះសាលាដំបូងថា អង្គជំនុំជម្រះមានបំណងស្តាប់សេចក្តីសន្និដ្ឋានលើចំណុចនេះ ថាតើត្រូវបានបញ្ចូលនៅក្នុងសារណាកាត់សេចក្តីស្តាពរ ក្នុងសេចក្តីសន្និដ្ឋានចុងក្រោយ ឬនៅសវនាការផ្ទាល់មាត់ស្តីពីការផ្តន្ទាទោសណាមួយ។ មូលដ្ឋាននៃសេចក្តីសន្និដ្ឋានទាំងនេះ គឺគោលការណ៍ដែលត្រូវបានបង្កើតឡើងដែលថាឆន្ទានុសិទ្ធិផ្តាច់មុខក្នុងការកំណត់អំពីទោសសមស្រប គឺជាភារកិច្ច

---

[1] ប្រតិចារឹក ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩, ទំព័រ៥០: លោក រូ: "រឿងនេះបានផ្តល់ឱកាសឲ្យខ្ញុំរម្លឹកឡើងវិញថា ដើមបណ្តឹងរដ្ឋប្បវេណីមិនមានតួនាទីដើម្បីបំពេញនៅក្នុងដំណើរការនីតិវិធីពាក់ព័ន្ធនឹងការផ្តន្ទាទោសនោះទេ"។ សូមមើល ប្រតិចារឹក ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៩, ទំព័រ៧: "សហព្រះរាជអាជ្ញានឹងនិយាយក្នុងនាមសាធារណជនក្នុងនាមសង្គម ដើម្បីទាមទារឲ្យការផ្តន្ទាទោសត្រូវបានអនុវត្ត។ នេះមិនមែនជាតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីទេ"។

[2] *រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ជ, ចម្លើយតបរបស់ក្រុមមេធាវីការពារ និងឯកសារទាំងឡាយដែលដាក់តម្កល់ដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១, ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៩, កថាខណ្ឌ៣ ("ចម្លើយតបរបស់ក្រុមមេធាវីការពារ")។

[3] ប្រតិចារឹក ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៩, ទំព័រ១១-១៣ (Ms. Studzinsky និង លោក ហុង គីមសួន), ទំព័រ១៦-២១ (លោក ខន)។ *សូមមើលផងដែរ រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ជ, ការឆ្លើយតបរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ ចំពោះចម្លើយតបរបស់សហមេធាវីការពារក្តីស្តីពីឈ្មោះសាក្សីនិងបញ្ជីឈ្មោះឯកសារ, ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៩។

របស់អង្គជំនុំជម្រះសាលាដំបូង[4]។ CPG-1 និង CPG-2 មិនបានសុំ ហើយនាពេលនេះក៏មិនបានស្នើឱ្យមានការដាក់ទោសពិសេសណាមួយដែរ។ ការស្តាប់សេចក្តីសន្និដ្ឋានរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី នឹងមិនរាំងស្ទះដល់ឆន្ទានុសិទ្ធិដ៏ទូលំទូលាយដែលអង្គជំនុំជម្រះមានក្នុងការកំណត់អំពីទោសរបស់ជនត្រូវចោទនោះទេ ។ ផ្ទុយទៅវិញការស្តាប់នោះនឹងអនុញ្ញាតឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការផ្តន្ទាទោស ដែលអាចធ្វើឱ្យមានធម្មានុរូបភាពដែលផ្តើមចេញពីការពិចារណាលើការយល់ឃើញរបស់បុគ្គលទាំងឡាយដែលត្រូវបានផ្តល់តួនាទីពិសេសតែមួយគត់ គឺធ្វើការជូនដំណឹងដល់អង្គជំនុំជម្រះពាក់ព័ន្ធនឹងផលប៉ះពាល់ជាក់ស្តែងដែលកើតមកពីអំពើនិងការប្រព្រឹត្តរបស់ជនត្រូវចោទការសម្តែងចេញនូវវិប្បដិសារីរបស់ជនត្រូវចោទ និងការសារភាពរបស់ជនត្រូវចោទ។

## II. ប្រវត្តិ

៣. នៅក្នុងពេលសវនាការបឋម សហមេធាវីការពារក្តីបាននិយាយថា ខ្លួនប្រឆាំងជំទាស់ទៅនឹងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងបញ្ហាផ្តន្ទាទោស[5]។ ពុំមានការគាំទ្រផ្នែកយុត្តិសាស្ត្រ ឬផ្នែកនីតិបញ្ញត្តិ ចំពោះគោលជំហររបស់សហមេធាវីការពារក្តីនេះទេ។ ក្នុងនាម CPG-1 និងយោងតាមវិធានផ្ទៃក្នុង លោក Khan បានជំទាស់ទៅនឹងគោលជំហររបស់សហមេធាវីការពារក្តី ព្រមទាំងបានថ្លែងថា *"ដោយដើមបណ្តឹងរដ្ឋប្បវេណីគឺជាភាគីដែលមានឋានៈស្មើភាពគ្នានឹងមិត្តដែលមានចំណេះដឹងជ្រៅជ្រះរបស់ខ្ញុំសម្រាប់ការការពារ*

---

[4] គោលការណ៍នេះរួមបញ្ចូលទាំងយុត្តាធិការជាតិនិងអន្តរជាតិ។ សូមមើល Roche ឆ្នាំ១៩៩៩-២ Cr.App.R. (S.) ១០៥ per Lord Bingham C.J. ដែលកំណត់គោលការណ៍ដែលត្រូវបានអនុវត្តតាមដោយតុលាការ នៅពេលប្រឈមនឹងការផ្តល់យោបល់របស់ជនរងគ្រោះទៅលើការផ្តន្ទាទោស: "ជាការពិត វាជាគោលការណ៍នៃការផ្តន្ទាទោសដ៏សំខាន់សម្រាប់តុលាការឆ្លងកាត់នូវអ្វីដែលខ្លួនបានវិនិច្ឆ័យដើម្បីធ្វើការផ្តន្ទាទោសឱ្យបានត្រឹមត្រូវ ដោយពិចារណាចំពោះកាលៈទេសៈទាំងអស់ដែលពាក់ព័ន្ធនឹងបទល្មើសនិងជនល្មើស"។ ពាក់ព័ន្ធនឹងការផ្តន្ទាទោសនៅ ICTY និង ICTR សូមមើល Allison Danner "ការបង្កើតឋានានុក្រម នៃបទល្មើសនៅក្នុងច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិស្តីពីការផ្តន្ទាទោស" លេខ ៨៧ (ឆ្នាំ២០០១) ការពិនិត្យច្បាប់ Virgina ៤១៥ នៅ ៤៣៥: "អ្វីៗពីមុនរបស់ Nuremburg និងតូក្យូ បានធ្វើឱ្យសេចក្តីសន្និដ្ឋានកាន់តែ រឹងមាំឡើង ហើយក៏មានជាក់ស្តែងនៅក្នុងច្បាប់លក្ខន្តិកៈរបស់តុលាការដែលចៅក្រមរបស់តុលាការនានារីករាយនឹង ឆន្ទានុសិទ្ធិដ៏ទូលំទូលាយក្នុងការសម្រេចអំពីទោសដាក់ពន្ធនាគារតាមច្បាប់អន្តរជាតិ"។

[5] ប្រតិចារឹក ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩, ទំព័រ៥០; ប្រតិចារឹកចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៩, ទំព័រ៧។

*ក្ដីនិងមិត្តដែលមានចំណេះដឹងជ្រៅជ្រះរបស់ខ្ញុំសម្រាប់ការផ្ដន្ទាទោសនោះ ការសន្មតទុកជាមុនត្រូវតែថា ទំហំនៃសេចក្ដីសន្និដ្ឋានត្រូវតែដូចគ្នា និងស្មើភាពគ្នាចំពោះការចូលរួមដែលត្រូវបានអនុញ្ញាតដល់ព្រះរាជអាជ្ញានិងសហមេធាវីការពារក្ដី លើកលែងតែមានការហាមឃាត់ច្បាស់លាស់ប៉ុណ្ណោះ*"[6]។ ដូចដែលលោកស្រី Studzinsky បានលើកឡើងហើយថា វាមិនមានចែងនៅក្នុងវិធានផ្ទៃក្នុង ឬក៏នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា "CCP"អំពី"*ការហាមឃាត់ពាក់ព័ន្ធនឹងបញ្ហានេះទេ[...][ហេតុនេះ សិទ្ធិក្នុងការលើកឡើងពីការផ្ដន្ទាទោស] ត្រូវបានរាប់បញ្ចូលនិងជា ផ្នែកមួយនៃសិទ្ធិនៃការចូលរួមពេញលេញផងដែរ*"[7]។ សហមេធាវីការពារក្ដីក៏បានថ្លែងដែរថា ការអនុញ្ញាតសិទ្ធិ "*ក្នុងការទាមទារនូវការផ្ដន្ទាទោសពិសេស" ដល់ដើមបណ្ដឹងរដ្ឋប្បវេណី នឹងធ្វើឱ្យយុត្តិសាស្ត្ររបស់យើងដើរថយក្រោយ ពីព្រោះវានឹងនាំយើងឱ្យត្រលប់ទៅរកថ្ងៃសងសឹកផ្ទាល់តែម្ដង*"[8]។ លោក Khan បានឆ្លើយយ៉ាងច្បាស់លាស់ ចំណែកឯ CPG-1 បាននិយាយឡើងវិញម្ដងទៀត[9] ថា "*ដើមបណ្ដឹងរដ្ឋប្បវេណីដែលយើងខ្ញុំតំណាង [...] មិនត្រូវការសងសឹកនោះទេ។ ពួកគេមិនត្រូវការបង្ហូរឈាមនោះទេ។ ពួកគេត្រូវការយុត្តិធម៌*"[10]។

---

[6] ប្រតិចារឹក ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៩, ទំព័រ១៧។

[7] ប្រតិចារឹកចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៩, ទំព័រ១១។

[8] ប្រតិចារឹកចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៩, ទំព័រ៧។

[9] *រឿងក្ដី កាំង ហ្កេកអ៊ាវ* សំណុំរឿងលេខ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, ក្រុម១ -- ដើមបណ្ដឹងរដ្ឋប្បវេណីស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងជួយសម្រួលឱ្យមានការផ្សព្វផ្សាយដល់ភាគីនូវរបាយការណ៍របស់ UN-OIOS, ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៩, កថាខណ្ឌ១៧។

[10] លោក Khan ប្រតិចារឹក ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៩, ទំព័រ២០។ ការតាក់តែងនេះត្រូវបានគាំទ្រតាមរយៈការសិក្សាស្រាវជ្រាវ ដែលបានរកឃើញថា ប្រជាជនកម្ពុជាតែមួយចំនួនតូចប៉ុណ្ណោះ - ប្រជាជនដែលមានចំនួនតិចជាងនៅក្នុងតំបន់ ដែលមានវិវាទ ឬតំបន់ក្រោយពីមានវិវាទ គួរឱ្យកត់សម្គាល់ - បានមើលឃើញការសងសឹកគឺជាគោលបំណងក្នុងការដាក់ បណ្ដឹងប្រឆាំងនឹងចារីដែលរំលោភលើសិទ្ធិមនុស្ស។ ជាងនេះទៅទៀត ប្រជាជនកម្ពុជាភាគច្រើនជឿថា ផលប្រយោជន៍ ដំបូងនៃការផ្ដន្ទាទោសឧក្រិដ្ឋកម្មសង្គ្រាមដែលត្រូវបានប្រព្រឹត្តនៅក្នុងប្រទេសរបស់ខ្លួន នឹងមានលក្ខណៈជាសហគមន៍រួម ទាំងមូល មិនមែនជនរងគ្រោះម្នាក់ៗនោះទេ។ សូមមើល Ernesto Kiza, Corene Rathgeber, Holger-C Rohne, ជនរងគ្រោះនៃសង្គ្រាម - ការស្រាវជ្រាវស្ដីពីការធ្វើឱ្យទៅជាជនរងគ្រោះដោយសារសង្គ្រាម និងឥរិយាបទរបស់ ជនរងគ្រោះចំពោះការរៀបរាប់ពីអំពើឃោរឃៅ', Hamburg 2006 ទំព័រ ១២២-១២៤។

៤. មិនមានការសម្រេចត្រូវបានធ្វើដោយអង្គជំនុំជម្រះលើចំណុចនេះទេ ទោះបីជានៅក្នុងពេលសវនាការបឋម ឬក្រោយមកទៀតក៏ដោយ។ នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៩ CPG-1 បានដាក់បញ្ជីឈ្មោះសាក្សីនិងឯកសារដែលត្រូវបានដកផ្នែកខ្លះចេញ[11]។ នៅក្នុងចម្លើយតបរបស់ខ្លួនទៅនឹងការដាក់បញ្ជីនេះ សហមេធាវីការពារក្តីបានធ្វើការតវ៉ាម្តងទៀតថា *"ដើមបណ្តឹងរដ្ឋប្បវេណី មិនត្រូវបានអនុញ្ញាតឱ្យលើកជូនតុលាការពាក់ព័ន្ធនឹងការផ្តន្ទាទោសនោះទេ"*[12]។ នៅក្នុងការឆ្លើយតបរបស់ខ្លួនចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៩ CPG-1 បានតវ៉ាថានៅក្នុងការលើកឡើងពីបញ្ហាសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការធ្វើសេចក្តីសន្និដ្ឋានស្តីពីការផ្តន្ទាទោសនោះ សហមេធាវីការពារក្តីបាន *"កំពុងសុំឱ្យមានការសម្រេចលើបញ្ហានេះ នៅពេលដែលបញ្ហានេះវាហួសឆ្ងាយពីក្របខណ្ឌ ក្នុងការដាក់ឯកសារដោយ CPG-1"*[13]។ យោងតាមចំណុចនេះ CPG-1 ក៏បានស្នើថា *"គ្មានសេចក្តីសម្រេចណាដែលត្រូវបានធ្វើដោយមិនបានផ្តល់ឱកាសដល់ភាគីលើកឡើងនូវបញ្ហាដាច់ដោយឡែក និងមានសារៈសំខាន់នេះដូចដែលមានចែងដោយវិធានផ្ទៃក្នុងដូច្នោះឡើយ"*[14]។

៥. អស់រយៈពេលជិតពីរខែកន្លងមកហើយមកទល់នឹងពេលនេះ ដែលពុំមានការផ្តល់ឱកាសណាមួយដល់ភាគីក្នុងការធ្វើសេចក្តីសន្និដ្ឋានលើបញ្ហាដ៏សំខាន់នេះទេ។ ហេតុដូច្នេះ CPG-1 និង CPG-2 បានធ្វើទឡ្ហីករណ៍ដូចខាងក្រោម ដើម្បីគាំទ្រដល់សំណើសុំសេចក្តីសម្រេចពីអង្គជំនុំជម្រះ ដោយសារតែភាពចាំបាច់ដើម្បីដោះស្រាយលើបញ្ហាសំខាន់នេះឱ្យបានទាន់ពេលវេលា។

## III. ទឡ្ហីករណ៍

---

[11] *រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ង, បញ្ជីឈ្មោះសាក្សីនិងឯកសារ របស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី (ក្រុមទី១) ផ្នែកខ្លះត្រូវបានលុបចោល, ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៩, ឯកសារលេខ E5/12 ។

[12] ចម្លើយតបរបស់ក្រុមមេធាវីការពារ, កថាខណ្ឌ១០។

[13] *រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ង, ការឆ្លើយតបរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ ចំពោះចម្លើយតបរបស់សហមេធាវីការពារក្តីស្តីពីឈ្មោះសាក្សីនិងបញ្ជីឈ្មោះឯកសារ, ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៩, កថាខណ្ឌ៩។

[14] *ដូចជើងទំព័រខាងលើ។*

## គ. ក្របខណ្ឌនៃ "សេចក្ដីសន្និដ្ឋានស្ដីពីការផ្ដន្ទាទោស"

៦. CPG-1 និង CPG-2 ស្នើសុំការអះអាងពីអង្គជំនុំជម្រះថា អង្គជំនុំជម្រះនឹងស្ដាប់សេចក្ដីសន្និដ្ឋានស្ដីពីការផ្ដន្ទាទោសរបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។ ត្រង់ចំណុចនេះ ការបែងចែកដាច់ពីគ្នាត្រូវតែធ្វើរវាងសេចក្ដីសន្និដ្ឋានទាក់ទិននឹង "ពិរុទ្ធភាព" និងសេចក្ដីសន្និដ្ឋានទាក់ទិនទាំងស្រុងនឹង "ការផ្ដន្ទាទោស"។ សេចក្ដីសន្និដ្ឋានដែលទាក់ទិននឹងពិរុទ្ធភាព នឹងលើកបង្ហាញយ៉ាងច្បាស់លាស់ ថាតើភស្ដុតាងមានដែរឬទេ ដែលអាចធ្វើជាមូលដ្ឋានដើម្បីបង្ហាញនូវការពិតថាជនត្រូវចោទបានប្រព្រឹត្តបទឧក្រិដ្ឋនីមួយៗ ដូចដែលត្រូវបានចោទប្រកាន់។ ផ្ទុយទៅវិញ សេចក្ដីសន្និដ្ឋានពាក់ព័ន្ធនឹងការផ្ដន្ទាទោសរួមមានបញ្ហាដូចជាផលប៉ះពាល់ដែលកើតមកពីការប្រព្រឹត្តឧក្រិដ្ឋកម្មរបស់ជនជាប់ចោទលើដើមបណ្ដឹងរដ្ឋប្បវេណីនិងក្រុមគ្រួសាររបស់ពួកគេ ភាពពាក់ព័ន្ធនឹងការសម្ដែងចេញនូវវិប្បដិសារីណាមួយ ព្រមទាំងផលនៃការសារភាពរបស់ជនត្រូវចោទ។ សេចក្ដីសន្និដ្ឋានទាំងនេះ នឹងប្រើប្រាស់នូវការធ្វើសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ៗ។ សេចក្ដីសន្និដ្ឋានស្ដីពីការផ្ដន្ទាទោស នឹងរួមបញ្ចូលផងដែរនូវសេចក្ដីសន្និដ្ឋានដែលពាក់ព័ន្ធនឹងទម្ងន់ទោស[15]ព្រមទាំងការពិភាក្សាអំពីផលប៉ះពាល់ (ប្រសិនបើ មាន) នៃស្ថានទម្ងន់ទោសឬស្ថានសម្រាលទោសផងដែរ។

៧. ប្រភេទនៃការទទួលខុសត្រូវ នឹងមានផលប៉ះពាល់ដល់ទោសដែលត្រូវបានដាក់ផងដែរ។ ហេតុនេះ សេចក្ដីសន្និដ្ឋានអំពីការផ្ដន្ទាទោសត្រូវគ្របដណ្ដប់លើការពិភាក្សាពីផលប៉ះពាល់ដែលកើតមកពីប្រភេទនៃការទទួលខុសត្រូវជាចាំបាច់ផងដែរ ដែលតាមរយៈនេះ ជនត្រូវចោទត្រូវទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនៅទីបំផុត។ ឧទាហរណ៍: តុលាការអន្តរជាតិបានលើកឡើងថា ការជួយនិងជម្រុញគឺជាប្រភេទនៃការទទួលខុសត្រូវ ដែលអនុញ្ញាត

---

15 សូមមើល ព្រះរាជអាជ្ញា តទល់នឹង Delalic IT-96-A សាលក្រម ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ ៧៣១។ ព្រះរាជអាជ្ញា តទល់នឹង Kupreskic et al IT-95-16-A សាលក្រម ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០១ កថាខណ្ឌ ៤៤២ ត្រង់កន្លែងដែលលើកឡើងដោយ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ថា ស្ថានទម្ងន់នៃបទល្មើសគឺជាការពិចារណាដំបូងគេក្នុងការដាក់ទោស។

ឱ្យមានការផ្តន្ទាទោសស្រាលជាងការទទួលខុសត្រូវរបស់សហចារី[16]។ ចំពោះការទទួលខុសត្រូវតាមរយៈការចូលរួមនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួមវិញ មានការលើកឡើងថា ប្រភេទនៃការចូលរួមមិនផ្ទាល់ នៅក្នុងសហកម្មឧក្រិដ្ឋកម្មរួមក៏អាចអនុញ្ញាតឱ្យមានការដាក់ទោសស្រាលជាងផងដែរ[17]។ ហើយនៅពេលដែលមានភាពច្បាស់លាស់ថា ជនជាប់ចោទមិនអាចផ្អែកលើការការពារដែលកើតចេញមកពីការបង្ខិតបង្ខំ ឬ បទបញ្ជារបស់ថ្នាក់លើនោះទាំងនេះ គឺជាកត្តាដែលអាចយកទៅធ្វើការពិចារណាបានយ៉ាងសមរម្យនៅពេលផ្តន្ទាទោស[18]។ ហេតុនេះ សេចក្តីសន្និដ្ឋានណាមួយពាក់ព័ន្ធនឹងការផ្តន្ទាទោសនឹងរួមបញ្ចូលនូវការពិភាក្សាអំពីការប្រតិបត្តិដែលពាក់ព័ន្ធនេះជាចាំបាច់។

៨. ផលប៉ះពាល់ដែលកើតមកពីការយល់ឃើញថា ជនត្រូវចោទបានធ្វើសកម្មភាពតាមបទបញ្ជារបស់ថ្នាក់លើនោះ មានការពាក់ព័ន្ធជាពិសេសនៅក្នុងកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ន ដោយសហមេធាវីការពារក្តីបានអះអាងថា ជនត្រូវចោទបានប្រតិបត្តិការងារនៅក្នុងរង្វង់រចនាសម្ព័ន្ធបញ្ជាដ៏តឹងរឹងមួយ។ ផលដែលកើតមកពីការចូលរួមរបស់ជនជាប់ចោទនៅក្នុងក្របខណ្ឌរចនាសម្ព័ន្ធបញ្ជានេះ នៅចុងបញ្ចប់អាចមានតម្លៃសំខាន់ណាស់ សម្រាប់កិច្ចដំណើរការនីតិវិធី និងមានការពាក់ព័ន្ធនឹងការផ្តន្ទាទោសផ្ទាល់តែម្តង។ ការហាមឃាត់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីកុំឱ្យចូលរួមក្នុងការពិភាក្សានេះ នឹងមានផលប៉ះពាល់ជាការបដិសេធមិនឱ្យដើមបណ្តឹងរដ្ឋប្បវេណីចូលរួមក្នុងបញ្ហា ដែលមានសារៈសំខាន់បំផុតក្នុងការកាត់សេចក្តីហើយនឹងជាការឃ្លាតចេញពីគោលការណ៍ដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង ដែលថា ដើមបណ្តឹងរដ្ឋប្បវេណីអាចចូលរួមក្នុងកិច្ចដំណើរការនីតិវិធីនោះប្រាកដណាស់។ ហេតុដូច្នេះ CPG-1 និង CPG-2 ស្នើសុំការអះអាងថា ខ្លួននឹងត្រូវបានគេស្តាប់អំពីបញ្ហាទាំងនេះ ដែលបញ្ហាទាំងនេះ សុទ្ធតែស្ថិតនៅក្នុងក្របខណ្ឌនៃសេចក្តីសន្និដ្ឋានស្តីពីការផ្តន្ទាទោសយ៉ាងសមស្រប។

---

16 *រឿងក្តីរដ្ឋអាជ្ញា តទល់ Vasiljević,* IT-98-32-A, សេចក្តីសម្រេច, ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៤, កថាខណ្ឌ១៨២។

17 *រឿងក្តីរដ្ឋអាជ្ញា តទល់ Krstić,* IT-98-33-A, សេចក្តីសម្រេច, ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៤, កថាខណ្ឌ២៦៨។

18 *រឿងក្តីរដ្ឋអាជ្ញា តទល់ Bralo,* IT-95-17-S, សាលក្រមផ្តន្ទាទោស, ចុះខែធ្នូ ឆ្នាំ២០០៥, កថាខណ្ឌ៧២។

## ខ. វិធានផ្ទៃក្នុងអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើសេចក្តីសន្និដ្ឋានស្តីពីការផ្តន្ទាទោស

៩. ដូចដែលសហមេធាវីតំណាង CPG-1 និង CPG-2 បានលើកឡើងនៅក្នុងពេលសវនាការបឋមរួចមកហើយ ពុំមានបញ្ញត្តិណាមួយនៅក្នុងវិធានផ្ទៃក្នុងដែលរារាំងមិនឲ្យមានការស្តាប់ដើមបណ្តឹងរដ្ឋប្បវេណីនិយាយអំពីការផ្តន្ទាទោសនោះឡើយ[19]។ ជាដំបូង វិធាន ២៣(៦)(ក) នៃវិធានផ្ទៃក្នុងបានចែងច្បាស់លាស់ថា "នៅពេលតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះក្លាយជាភាគីក្នុងដំណើរការនីតិវិធី"។ វិធាន ២៣(១)(ក) បានកំណត់អំពីសិទ្ធិចូលរួមយ៉ាងទូលំទូលាយរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងដំណើរការនីតិវិធីរបស់អ.វ.ត.ក និងបានចែងថា គោលបំណងក្នុងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីគឺដើម្បី:

> ក) **ចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ** ប្រឆាំងនឹងអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ដោយគាំទ្រដល់ការចោទប្រកាន់...

១០. វិធាន ដ៏សំខាន់នេះដែលគ្រប់គ្រងការចូលរួមក្នុងដំណើរការនីតិវិធីនៅអង្គជំនុំជម្រះវិសាមញ្ញរបស់ដើមបណ្តឹងរដ្ឋប្បវេណី អាចត្រូវបានព្រាងឡើងដោយមានភាពចង្អៀតជាងនេះទៀត។ ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវបានរៀបចំដោយប្រើពាក្យពេចន៍ពិសេសពាក់ព័ន្ធនឹងការមានសិទ្ធិក្នុងការ"រួមចំណែកដល់" ឬ ក្នុងការ "ជួយនៅក្នុង" ដំណើរការនីតិវិធីព្រហ្មទណ្ឌ។ ផ្ទុយទៅវិញ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានអនុញ្ញាតយ៉ាងជាក់លាក់ឲ្យ"**ចូលរួម**" នៅក្នុងដំណើរការនីតិវិធី ដោយបង្ហាញនូវសិទ្ធិដ៏ទូលំទូលាយនានា និងវិធីសាស្ត្ររួមបញ្ចូលទាំងអស់របស់តុលាការ។

---

[19] ប្រតិចារិកចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៩, ទំព័រ១១ (Ms. Studzinsky), ទំព័រ១២ (លោក ហុង គឹមសួន), ទំព័រ១៧ (លោក Khan)។

១១. ដូច្នេះ វិធាន ៩១(១) នៃវិធានផ្ទៃក្នុងបានកំណត់ពីបទបញ្ញត្តិទូទៅថា ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានគេស្តាប់ចម្លើយ។ នៅពេលដែលសិទ្ធិក្នុងការចូលរួមយ៉ាងទូលំទូលាយ របស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានហាមឃាត់ ចំណុចនេះត្រូវបានចែងយ៉ាងជាក់លាក់នៅក្នុងវិធានផ្ទៃក្នុង។ ឧទាហរណ៍: វិធាន ៨២(៣) ដែលទាក់ទងនឹងការ ឃុំខ្លួនបណ្តោះអាសន្ន និងការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបាន ចែងថា អង្គជំនុំជម្រះត្រូវសម្រេចសេចក្តី "*បន្ទាប់ពីបានស្តាប់ជនជាប់ចោទមេធាវី ជនជាប់ចោទ និងសហព្រះរាជអាជ្ញា*"។ ពុំមានបញ្ញត្តិណាចែងអំពីការធ្វើសេចក្តីសន្និដ្ឋានរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។ វិធាន ១០៥(១)(គ) នៃវិធានផ្ទៃក្នុង ចែងថា "បណ្តឹងសារទុក្ខអាចធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី[...]តែក្នុងករណីដែលមានបណ្តឹងសារទុក្ខរបស់សហព្រះរាជអាជ្ញានៅក្នុងរឿងនោះតែប៉ុណ្ណោះ"។ យោងតាមបញ្ញត្តិនេះ វិធានផ្ទៃក្នុងបានបញ្ជាក់ច្បាស់លាស់ថាពេលណាអង្គជំនុំជម្រះនឹងស្តាប់តែសហព្រះរាជអាជ្ញា និងជនជាប់ចោទប៉ុណ្ណោះ ឬថា សិទ្ធិនានារបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានហាមឃាត់។ ប្រសិនបើគ្មានការគូសបញ្ជាក់បែបនេះធ្វើឡើងទេ ក៏គ្មានដែនកំណត់ណាមួយដែរ។

១២. សហមេធាវីការពារក្តីមិនត្រូវបានបើកផ្លូវឲ្យតវ៉ាថា ការមិនអនុញ្ញាតឲ្យបានច្បាស់លាស់នៅក្នុងវិធានផ្ទៃក្នុង បានរារាំងសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនឲ្យធ្វើសេចក្តីសន្និដ្ឋានអំពីការផ្តន្ទាទោសនោះទេ។ ចំណុចនេះត្រូវបានបង្ហាញយ៉ាងច្បាស់តាមរយៈឧទាហរណ៍។ វិធានផ្ទៃក្នុងផ្តល់សិទ្ធិដល់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការស្នើសុំ "សំណងសមូហភាពនិងសំណងផ្លូវចិត្ត" ស្របតាមវិធាន ២៣(១)(ខ)។ វិធាន ៩៤(១) នៃវិធានផ្ទៃក្នុងអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល។ ពុំមានដែនកំណត់ណាមួយត្រូវបានដាក់ទៅលើវិសាលភាពនៃវិធាននេះទេ។ ហេតុដូច្នេះ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែអាចធ្វើសេចក្តីសន្និដ្ឋានពាក់ព័ន្ធនឹងសំណងនៅក្នុងពេលធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល។ វាមិនសមហេតុផលទាល់តែសោះក្នុងការអនុញ្ញាតសិទ្ធិដល់ភាគីរួចហើយបែរជារារាំងភាគីនោះមិនឲ្យធ្វើសេចក្តីសន្និដ្ឋានដែលពាក់ព័ន្ធទៅនឹងសិទ្ធិនោះផ្ទាល់។ វិធាន ៩៤(១) មិនបានចែងច្បាស់លាស់អំពីការធ្វើសេចក្តីសន្និដ្ឋានរបស់ដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងសំណងនៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលនោះទេ ប៉ុន្តែវាពុំមានការសង្ស័យទេថាសិទ្ធិនេះនៅ

តែមាន។ ការផ្តល់ហេតុផលដូចគ្នានេះអនុវត្តផងដែរចំពោះសេចក្តីសន្និដ្ឋានអំពីការផ្តន្ទាទោសរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

១៣. កិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង មិនត្រូវបានបែងចែកនោះទេ ហើយវាក៏មិនទំនងជា អាចកើតឡើងដែរ។ វិធាន ៩៨(៥) និង (៦) នៃវិធានផ្ទៃក្នុងចែងថា សាលក្រមមួយនឹងត្រូវចេញដែលបង្ហាញពីពិរុទ្ធភាពរបស់ជនត្រូវចោទនិងប្រកាសអំពីទោស ។ ពុំមានបញ្ញត្តិណាចែងពីសវនាការ និងសាលក្រមដោយឡែកពីគ្នាអំពីបញ្ហាផ្តន្ទាទោសនោះទេ អង្គជំនុំជម្រះក៏មិនបានបង្ហាញថា វានឹងក្លាយជាវិធីសាស្ត្រដែលត្រូវបានប្រកាន់យកនោះដែរ។ ប្រការនេះផ្តល់ការគាំទ្របន្ថែមដល់គោលជំហរដែលភាគីទាំងអស់អាចជជែកតវ៉ាបាននៅគ្រប់ទិដ្ឋភាពទាំងអស់រួមទាំងទិដ្ឋភាពពាក់ព័ន្ធនឹងការផ្តន្ទាទោសជនត្រូវចោទទាំងនោះផងដែរ។

១៤. មានការទទួលស្គាល់ថា អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិដ៏ទូលំទូលាយក្នុងការគ្រប់គ្រងដំណើរការនីតិវិធី និង ក្នុងការ "ដឹកនាំសវនាការ"[20]។ អនុលោមតាមវិធាន ៨៥ ដោយមានការពិគ្រោះយោបល់ជាមួយចៅក្រមផ្សេងទៀត ប្រធានសវនាការ "*អាចបដិសេធនូវរាល់នីតិវិធីដែលនាំឱ្យមានការពន្យាពេលដល់ការជំនុំជម្រះ និងដែលមិនអាចនាំទៅដល់ការស្វែងរកការពិត*" និង "*ត្រូវធានារ៉ាប់រងឱ្យមានសណ្តាប់ធ្នាប់ល្អក្នុងពេលសវនាការ*"។ ទោះបីជាយ៉ាងណាក៏ដោយ ឆន្ទានុសិទ្ធិនេះមិនមានវិសាលភាពរហូតដល់កម្រិតសិទ្ធិនានារបស់ភាគី ដែលការកម្រិតនោះមិនមានការគាំទ្រនៅក្នុងវិធានផ្ទៃក្នុងនោះទេ។ អង្គជំនុំជម្រះសាលាដំបូងមិនអាចសម្រេចសេចក្តីថា ខ្លួនមិនមានបំណងស្តាប់ចម្លើយរបស់ភាគីអំពីបញ្ហាពិសេសណាមួយទេ ក្នុងករណីដែលលទ្ធភាពក្នុងការធ្វើសេចក្តីសន្និដ្ឋានរបស់ភាគីនោះ មិនត្រូវបានកំណត់ជាក់លាក់ដោយច្បាប់គ្រប់គ្រងតុលាការទេនោះ។ អង្គជំនុំជម្រះសាលាដំបូងនឹងដើរតួ *ក្រៅយុត្តាធិការរបស់តុលាការ* ប្រសិនបើអង្គជំនុំជម្រះបានសម្រេចថា នឹងមិនស្តាប់ចម្លើយរបស់ជនត្រូវចោទអំពីការដោះលែងជាបណ្តោះអាសន្នឬថាអង្គជំនុំជម្រះនឹងមិនអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាធ្វើសេចក្តីសន្និដ្ឋាន

---

[20] វិធានផ្ទៃក្នុង ៩០(១)៖ ប្រធានអង្គជំនុំជម្រះត្រូវប្រាប់ដល់ជនជាប់ចោទអំពីសិទ្ធិរបស់ខ្លួនដូចមានចែងក្នុងវិធាន ២១(១)(ឃ) និងដឹកនាំសវនាការ។

បើកទេនោះ។ អង្គជំនុំជម្រះសាលាដំបូងនឹងដើរតួ *ក្រៅយុត្តាធិការ របស់តុលាការ* ដូចគ្នា ប្រសិនបើអង្គជំនុំជម្រះបដិសេធមិនស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីអំពីការផ្តន្ទាទោសទេនោះ។ សូមសន្និដ្ឋានដោយគោរពថា ឆន្ទានុសិទ្ធិដ៏ទូលំទូលាយរបស់អង្គជំនុំជម្រះក្នុងការដឹកនាំដំណើរការនីតិវិធីនោះ មិនគ្របដណ្តប់លើការហាមឃាត់ដែលមិនមានការគាំទ្រនៅក្នុងច្បាប់គ្រប់គ្រងតុលាការនោះទេ។ វិធាន ផ្ទៃក្នុងត្រូវបានព្រាងរួចហើយ ហើយត្រូវបានធ្វើវិសោធនកម្មចំនួនបីដង[21]។ ប្រសិនបើអ្នកធ្វើសេចក្តីព្រាងមានបំណងហាមឃាត់សិទ្ធិនានាពាក់ព័ន្ធនឹងការធ្វើសេចក្តីសន្និដ្ឋានអំពីការផ្តន្ទាទោសរបស់ដើមបណ្តឹងរដ្ឋប្បវេណីមែន ការហាមឃាត់នេះនឹងត្រូវបានព្រាងឡើងយ៉ាងច្បាស់លាស់ជាមិនខាន។ ប៉ុន្តែវាមិនមែនដូច្នេះទេ។

១៥. ទោះបីជាអង្គជំនុំជម្រះសាលាដំបូងមើលវិធានផ្ទៃក្នុងក្នុងផ្លូវផ្សេងៗគ្នា និងពិចារណាឃើញថា បញ្ហាជំហររបស់ដើមបណ្តឹងរដ្ឋប្បវេណី មិនត្រូវបានសម្រេចច្បាស់លាស់ត្រង់ចំណុចនោះក៏ដោយ ចំណុចពាក់ព័ន្ធនេះត្រូវតែមានចែងនៅក្នុងវិធាន ២ នៃវិធានផ្ទៃក្នុង។ វិធាន ២ នៃវិធានផ្ទៃក្នុងបានចែងថា នៅក្នុងករណីមានការខ្វះចន្លោះមិនមានចែងនៅក្នុងវិធានផ្ទៃក្នុងអង្គជំនុំជម្រះត្រូវធ្វើការសម្រេចចិត្ត ដោយស្របតាមមាត្រា ១២-១ នៃកិច្ចព្រមព្រៀង និងមាត្រា ២០ថ្មី, ២៣ថ្មី, ៣៣ថ្មី ឬ ៣៧ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញដែលមានជាធរមាន និងដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើគោលការណ៍ជាមូលដ្ឋាន ដែលមានចែងក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុងនេះ និងច្បាប់នីតិវិធីព្រហ្មទណ្ឌជាធរមាន..."។

១៦. ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញបានចែងថា អង្គជំនុំជម្រះអាចស្វែងរកការណែនាំនៅក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ។ ដូចនៅអ.វ.ត.ក ដែរ នីតិវិធីតុលាការឧក្រិដ្ឋកម្មអន្តរជាតិ បានចែងអំពីគម្រោងរៀបចំការចូលរួមដ៏ទូលំទូលាយរបស់ជនរងគ្រោះ។ នៅពេលដែលគ្មានរឿងក្តីណាមួយនៅចំពោះមុខតុលាការឧក្រិដ្ឋកម្មអន្តរជាតិបានឈានទៅដល់ដំណាក់កាលផ្តន្ទាទោសនោះ មានការបង្ហាញខ្លះៗ

[21] វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី១), ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០០៨; វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី២), ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៨, វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៣), ចុះថ្ងៃទី៦ ខែមីនា ឆ្នាំ២០០៩។

ពាក់ព័ន្ធនឹងវិធីសាស្ត្រដែលនឹងត្រូវចាត់វិធានការ ទាក់ទិននឹងគោលជំហរក្នុងការធ្វើសេចក្តីសន្និដ្ឋានអំពីការផ្តន្ទាទោសរបស់ជនរងគ្រោះ។ ហេតុផលរបស់អង្គបុរេជំនុំជម្រះក្នុងរឿងក្តី Katanga កំណត់ថា ផលប្រយោជន៍របស់ជនរងគ្រោះនៅក្នុងកិច្ចដំណើរការនីតិវិធី "បានឈានហួសពីការកំណត់ពីអ្វីដែលបានកើតឡើង និងអំពីការបង្ហាញអត្តសញ្ញាណនៃអ្នកដែលទទួលខុសត្រូវទាំងនោះ និងគ្របដណ្តប់លើការធានាអំពីកម្រិតច្បាស់លាស់នៃការដាក់ទណ្ឌកម្មអ្នកទាំងឡាយណាដែលបានទទួលខុសត្រូវ ក្នុងការប្រព្រឹត្តនូវឧក្រិដ្ឋកម្មដែលជនរងគ្រោះទាំងនោះបានទទួលរងនូវការខូចខាតដ៏ឈឺចាប់នោះ"[22]។ សេចក្តីសន្និដ្ឋាននេះ ត្រូវបានអះអាងតាមរយៈការសិក្សាផ្អែកតាមបទពិសោធន៍ដ៏ទូលំទូលាយ និងតាមរយៈយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអន្តរអាមេរិកាំង (IACHR) និងតុលាការសិទ្ធិមនុស្សអឺរ៉ុប (ECHR)។ លើសពីនេះទៀត ការសិក្សានិងការបកស្រាយច្បាប់ បានគូសបញ្ជាក់ពីសេចក្តីត្រូវការវិធានការយុត្តិធម៌អន្តរកាល ដើម្បីយកផលប្រយោជន៍របស់ជនរងគ្រោះទៅធ្វើការពិចារណា ប្រយោជន៍ដើម្បីសម្រួលដល់ការផ្សះផ្សាគ្នានៅក្នុងសង្គមក្រោយមានជម្លោះ[23] និងធ្វើយុត្តិកម្មលើការអនុវត្តច្បាប់ព្រហ្មទណ្ឌអន្តរជាតិ[24] ព្រមទាំងការដាក់ទណ្ឌកម្មនានាដែលពាក់ព័ន្ធ។

១៧. ផ្ទុយទៅនឹងទឡ្ហីករណ៍របស់សហមេធាវីការពារក្តី ដែលបានស្នើសុំឱ្យបន្ថយក្របខណ្ឌ នៃផលប្រយោជន៍របស់ "ជនរងគ្រោះ" នោះ[25] តុលាការឧក្រិដ្ឋកម្មអន្តរជាតិបានលើកឡើង

---

[22] សូមមើល Prosecutor v. Germain Katanga and Mathieu Ngudjolo Chui, ICC-01/04-01/07 សេចក្តីសម្រេចស្តីពីក្រុមវិធាននីតិវិធីដែលភ្ជាប់ជាមួយលក្ខន្តិកៈនីតិវិធីរបស់ជនរងគ្រោះនៅដំណាក់កាលរឿងក្តីអង្គបុរេជំនុំជម្រះ អង្គបុរេជំនុំជម្រះ I (ចៅក្រមតែមួយ) ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ កថាខ័ណ្ឌ ៣៨ (ជើងទំព័រខាងក្នុងត្រូវបានលុបចោល)។

[23] សូមមើល Mark A. Drumbl, Atrocity និង ការផ្តន្ទាទោសនៅក្នុងច្បាប់អន្តរជាតិ (ឆ្នាំ២០០៧) ទំព័រ ១៣៣-១៣៨។

[24] Kiza, Rathgeber, et al., supra 10 ទំព័រ ១៦។ គណៈកម្មការសិទ្ធិមនុស្សឯករាជ្យអាហ្គានីស្ថាន ការអំពាវនាវរកយុត្តិធម៌ការពិគ្រោះយោបល់ថ្នាក់ជាតិស្តីពីការរំលោភលើសិទ្ធិមនុស្សកាលពីអតីតកាលនៅក្នុងប្រទេស អាហ្វហ្គានីស្ថាន ឆ្នាំ ២០០៦ ទំព័រ៥។

[25] លោក វូ បាននិយាយថា ដើមបណ្តឹងរដ្ឋប្បវេណីអាចត្រឹមតែធ្វើការអង្កេតតែប៉ុណ្ណោះនៅពេលដែលផលប្រយោជន៍របស់ ខ្លួនត្រូវបានប៉ះពាល់នោះ: "ហើយ នៅពេលដែលខ្ញុំកំពុងនិយាយអំពីផលប្រយោជន៍របស់ពួកគេ ខ្ញុំចង់រម្លឹក

នៅក្នុងរឿងក្តី Katanga ថា "ផលប្រយោជន៍ទាំងនេះ - ពោលគឺការបង្ហាញអត្តសញ្ញាណ ការចោទប្រកាន់ និងការដាក់ទណ្ឌកម្មទៅលើអ្នកទាំងឡាយណាដែលបានធ្វើឱ្យពួកគេរងគ្រោះដែលបានការពារមិនឱ្យអ្នកទាំងនោះរួចខ្លួន គឺស្ថិតនៅត្រង់មូលហេតុនៃសិទ្ធិក្នុងការទទួលបាននូវភាពយុត្តិធម៌ដែលត្រូវបានទទួលស្គាល់សម្រាប់ជនរងគ្រោះនៃអំពើរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរនោះ[26]។ សិទ្ធិនេះក៏ត្រូវបានទទួលស្គាល់ដោយតុលាការសិទ្ធិមនុស្សអឺរ៉ុប[27] តុលាការសិទ្ធិមនុស្សអន្តរអាមេរិកាំង[28] ការអត្ថាធិប្បាយច្បាប់[29] និងតុលាការនេះផងដែរ[30]។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិបានកត់សម្គាល់ឃើញថែមទៀត ថា "នៅពេលដែលសិទ្ធិនេះត្រូវបាន បំពេញតាមរយៈកិច្ចដំណើរការ នីតិវិធីព្រហ្មទណ្ឌនោះជនរងគ្រោះមានផលប្រយោជន៍សំខាន់មួយដែលនៅក្នុងនោះលទ្ធផលនៃកិច្ចដំណើរការនីតិវិធី នោះនាំដល់ការបង្ហាញអត្តសញ្ញាណ ការចោទប្រកាន់ និងការដាក់ទណ្ឌកម្មលើអ្នកទាំងឡាយណាដែលបានធ្វើឱ្យអ្នកទាំងនោះរងគ្រោះ"[31]។ ដើម្បីឱ្យមានការអនុវត្តសិទ្ធិនេះនៅពេលដែលជនរងគ្រោះ គឺជាភាគីនៃកិច្ចដំណើរការនីតិវិធី និងនៅពេលដែលការគាំទ្រការចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌរបស់ជនរងគ្រោះមានកម្រិតខ្ពស់គួរ

---

អ្នកថា ពួកយើងនិយាយតែពីសំណងដែលដើមបណ្តឹងរដ្ឋប្បវេណីអាចស្នើសុំប៉ុណ្ណោះ"។ ប្រតិចារឹកចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០០៩, ទំព័រ៩៩។

[26] *សូមមើលរឿងក្តីរដ្ឋអាជ្ញា តទល់ Katanga, ដូចខាងលើ* កណត់សម្គាល់ទី២២, កថាខណ្ឌ៣៩។

[27] Aydin v. Turkey (22492/93) សាលក្រម ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០០ កថាខណ្ឌ ៨៩-៩៣។ Kilic v. Turkey សាលក្រម ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៦ (៧០៨៤៥/០១) កថាខណ្ឌ ១០៣-១០៩។

[28] សូមមើល Velasquez Rodriguez សាលក្រម ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៨៨ Inter-Am. Ct.H.R. (Ser. C) លេខ ៤ (ឆ្នាំ១៩៨៨) កថាខណ្ឌ ១៧៤-១៧៦។ Vargas-Areco v. Rodriguez សាលក្រម ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៦ (អង្គសេចក្តី សំណង និងតម្លៃ) កថាខណ្ឌ ១៥៣។

[29] Kai Ambos ក្របខណ្ឌច្បាប់នៃភាពយុត្តិធម៌អន្តរកាលៈ ការសិក្សាជាលក្ខណៈប្រព័ន្ធដោយសម្តៅជាពិសេសលើតួនាទី របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ Heidelberg 2009 ទំព័រ៣៦ ត្រង់លេខជើងទំព័រ ១០១។

[30] សិទ្ធិទាំងនេះត្រូវបានទទួលស្គាល់ជា "ការព្រួយបារម្ភដ៏សំខាន់ដែលពាក់ព័ន្ធនឹងការអនុវត្តនូវនុសិទ្ធិរបស់អង្គជំនុំជម្រះ"នៅក្នុង"សេចក្តីណែនាំអំពីសិទ្ធិដែលមិនត្រូវបានតំណាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការបង្ហាញជូនអង្គបុរេជំនុំជម្រះ ដោយផ្ទាល់ខ្លួន" របស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៨ C22/I/69 កថាខណ្ឌ៨។

[31] *សូមមើលរឿងក្តីរដ្ឋអាជ្ញា តទល់ Katanga, ដូចខាងលើ* កណត់សម្គាល់ទី២២, កថាខណ្ឌ៤១។

ឲ្យកត់សម្គាល់នោះ[32] ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចត្រូវបានបដិសេធមិនឲ្យធ្វើសេចក្តីសន្និដ្ឋានអំពីការផ្តន្ទាទោសនោះទេ។

១៨. នៅទីបំផុត ទោះបីជាអង្គជំនុំជម្រះយល់ឃើញថា បញ្ហាគោលជំហររបស់ដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានសម្រេចដោយវិធានផ្ទៃក្នុង ឬបទដ្ឋាននីតិវិធីដែលត្រូវបានបង្កើតឡើង នៅកម្រិតអន្តរជាតិក៏ដោយ ចំណុចពាក់ព័ន្ធនេះត្រូវតែមានចែងនៅក្នុងមាត្រា ១២(១) នៃកិច្ចព្រមព្រៀង ដែលស្របតាមមាត្រានេះ អង្គជំនុំជម្រះត្រូវធ្វើការពិចារណាអំពីច្បាប់កម្ពុជា។ ត្រង់ចំណុចនេះ សហមេធាវីការពារក្តីបានតវ៉ាថា ច្បាប់កម្ពុជាគាំទ្រជំហររបស់ខ្លួន ដែលទំនងដោយសារហេតុថា ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាបានធ្វើការបែងចែករវាងដំណើរការនីតិវិធីរដ្ឋប្បវេណីនិងដំណើរការនីតិវិធីព្រហ្មទណ្ឌ[33]។ អំណះអំណាងរបស់សហមេធាវីការពារក្តីមានភាពមិនច្បាស់លាស់ ប៉ុន្តែអាចថា ដើមបណ្តឹងរដ្ឋប្បវេណីអាចដាក់បានតែ "ពាក្យបណ្តឹងរដ្ឋប្បវេណី" ប៉ុណ្ណោះ។ ឬក៏ សហមេធាវីការពារក្តីអាចតវ៉ាថា ដើមបណ្តឹងរដ្ឋប្បវេណីមានតែ "ផលប្រយោជន៍ផ្នែករដ្ឋប្បវេណី" ប៉ុណ្ណោះនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ហេតុនេះហើយទើបត្រូវគេបដិសេធមិនឲ្យធ្វើសន្និដ្ឋាននានាដូចជាអំពីការផ្តន្ទាទោសជាដើម។ អំណះអំណាងបែបនេះមួយណាក៏មិនអាចធ្វើឲ្យគេជឿបានទេ។ ច្បាប់កម្ពុជា ពិតជាធ្វើការបែងចែករវាងបណ្តឹងរដ្ឋប្បវេណី និងបណ្តឹងព្រហ្មទណ្ឌមែន។ ទោះបីជាយ៉ាងណាក៏ដោយ ដូចនៅអ.វ.ត.ក[34] ជនរងគ្រោះ អាចដាក់ពាក្យបណ្តឹងដើម្បីចូលរួមក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ និងក្លាយទៅជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបអង្កេត[35] ឬក្រោយមកទៀតក្លាយជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[36]។ អង្គហេតុ

---

[32] ក្នុងប្រទេសកម្ពុជា ៨២% នៃប្រជាជនដែលត្រូវបានសួរ បាននិយាយថាជនរងគ្រោះគួរតែចូលរួមក្នុងការកាត់សេចក្តីជនល្មើសដែលរំលោភសិទ្ធិមនុស្ស ចំនួននេះគឺខ្ពស់ជាងគេក្នុងបណ្តាប្រទេសមានទំនាស់ និងក្រោយទំនាស់ទាំង១១ ដែលត្រូវបានយកមកវិភាគ។ Kiza, Rathgeber, និងអ្នកផ្សេងទៀត, *ដូចខាងលើ* កំណត់សម្គាល់១០, ទំព័រ១០២-១០៤។

[33] ចម្លើយតបរបស់ក្រុមមេធាវីការពារ, កថាខណ្ឌ១២។

[34] វិធានផ្ទៃក្នុង ២៣(៦)(ក) និង ២៣(១)(ក)។

[35] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ១៣៧, ១៣៨។

[36] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា៣១១។

ដែលថាជនរងគ្រោះក៏អាចដាក់“បណ្តឹងរដ្ឋប្បវេណី”បានដែរនោះ[37] គឺមិនមានឧបសគ្គណាមួយរារាំងការចូលរួមរបស់ពួកគេនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌនោះឡើយ។

១៩. មាត្រា ២២ កំណត់អំពីភាពពាក់ព័ន្ធផ្នែកយុត្តាធិការរវាងតុលាការរដ្ឋប្បវេណីនិងតុលាការព្រហ្មទណ្ឌនៅក្នុងប្រទេសកម្ពុជា។ មាត្រានេះបានចែងថា “ បណ្តឹងរដ្ឋប្បវេណីអាចត្រូវបានធ្វើឡើងភ្ជាប់ជាមួយនឹងបណ្តឹងព្រហ្មទណ្ឌដែលនៅចំពោះមុខតុលាការព្រហ្មទណ្ឌ” និង “បណ្តឹងរដ្ឋប្បវេណីក៏អាចត្រូវបានធ្វើឡើងនៅចំពោះមុខតុលាការរដ្ឋប្បវេណីផងដែរ”។ មាត្រានេះ មិនបានកំណត់ព្រំដែននៃសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការចូលរួមក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ឬកំណត់ព្រំដែនសិទ្ធិក្នុងការចូលរួមរបស់ពួកគេនៅពេលដែលពួកគេចូលរួមក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌនោះទេ។

២០. ចំពោះបញ្ហាជាក់លាក់នៃគោលជំហររបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការធ្វើសេចក្តីសន្និដ្ឋានអំពីការផ្តន្ទាទោសនោះ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាមិនបានចែងនោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិដូចគ្នានឹងភាគីផ្សេងទៀតនៃដំណើរការនីតិវិធីក្នុងការផ្តល់ចម្លើយឱ្យគេស្តាប់[38]។ ជាសំខាន់ មាត្រា ៣៣៥ អនុញ្ញាត ឱ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើសេចក្តីសន្និដ្ឋានខ្លីៗនៅពេលចុងបញ្ចប់នៃសវនាការដែលមិនត្រូវបានគេកម្រិតខ្លឹមសារនៃសេចក្តីសន្និដ្ឋាននោះទេ។ សហព្រះរាជអាជ្ញា លោកស្រី ជា លាង បានពន្យល់ថានៅក្នុងពេលធ្វើសេចក្តីសន្និដ្ឋានចុងក្រោយនេះ ដើមបណ្តឹងរដ្ឋប្បវេណីធ្វើសេចក្តីសន្និដ្ឋានអំពីការផ្តន្ទាទោស។ គាត់បានជម្រាបអង្គជំនុំជម្រះថា “ នៅចុងបញ្ចប់នៃសវនាការតាមធម្មតា អង្គជំនុំជម្រះសាលាដំបូងសួរដើមបណ្តឹងរដ្ឋប្បវេណីអំពីថាតើពួកគេមានសំណូមពរអ្វីសម្រាប់អង្គជំនុំជម្រះយកទៅពិចារណា ឬទេ។ ពួកគេមិនត្រូវបានកម្រិតអំពីការបញ្ចេញមតិយោបល់នោះទេ។ យើងទាំងអស់គ្នា បានដឹងហើយថា ជាដំបូងពួកគេចង់ស្នើសុំសំណង ទោះបីជាយ៉ាងណាក៏ដោយ ពួកគេក៏អាចស្នើសុំឱ្យមានការដាក់ទោសទៅលើជនត្រូវចោទនោះផងដែរ”[39]។

[37] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា១៣។

[38] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា៣២៦។

[39] សវនាការបឋម, ប្រតិចារឹក ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៩, ទំព័រ១៤។

២១. សរុបមក CPG-1 និង CPG-2 សន្និដ្ឋានថា អង្គជំនុំជម្រះមិនត្រូវសម្លឹងមើលអ្វីផ្សេងថែមទៀតក្រៅពីវិធានផ្ទៃក្នុងនោះទេ ដែលផ្ដល់ដល់ដើមបណ្ដឹងរដ្ឋប្បវេណីនូវសិទ្ធិផ្ដល់ចម្លើយឱ្យគេស្ដាប់អំពីបញ្ហាការផ្ដន្ទាទោស។ ជម្រើសម្យ៉ាងទៀត យុត្តិសាស្ត្រអន្តរជាតិដែលបង្ហាញឱ្យឃើញគាំទ្រគោលជំហរនេះ ដូចច្បាប់កម្ពុជាដូច្នោះដែរ។ ដោយបានលើកឡើងថា សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានសិទ្ធិផ្ដល់ចម្លើយឱ្យគេស្ដាប់នោះ នាពេលនេះ CPG-1 និង CPG-2 នឹងលើកឡើងនូវសេចក្ដីសន្និដ្ឋានបន្ថែមទៀតពាក់ព័ន្ធនឹងមូលហេតុដែលខ្លួនគួរតែមានសិទ្ធិផ្ដល់ចម្លើយឱ្យគេស្ដាប់។

## គ. ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីពាក់ព័ន្ធផ្ទាល់នៅនឹងការផ្ដន្ទាទោស

២២. វិធាន ៩១(១) នៃវិធានផ្ទៃក្នុង ចែងថា អង្គជំនុំជម្រះសាលាដំបូងត្រូវស្ដាប់ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។ ស្របតាមវិធាននេះ នៅក្នុងសេចក្ដីណែនាំរបស់អង្គជំនុំជម្រះស្ដីពីការកំណត់ពេលវេលាសវនាការថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៩[40] អង្គជំនុំជម្រះបានបែងចែកភស្ដុតាងទៅតាមប្រធានបទ និងបានបង្ហាញថា អង្គជំនុំជម្រះនឹងសួរ "ដើមបណ្ដឹងរដ្ឋប្បវេណី" អំពីប្រធានបទផ្សេងៗគ្នាទាំងនេះ[41]។ សហមេធាវីតំណាង CPG-1 បានស្នើសុំការបំភ្លឺអំពីសេចក្ដីណែនាំនេះនៅក្នុងពេលដំណើរការនីតិវិធី ដោយបានលើកឡើងដូចខាងក្រោម៖

" [...] នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៩ អង្គជំនុំជម្រះបានចេញសេចក្ដីណែនាំមួយស្ដីពីការកំណត់ពេលវេលាសវនាការ និងនៅត្រង់ចំណុចទី៩ នៃសេចក្ដីណែនាំ មានការពន្យល់ឬបញ្ជាក់ថា ភស្ដុតាងនឹងត្រូវបានបែងចែកជាផ្នែក ហើយអង្គជំនុំជម្រះបានបង្ហាញឱ្យឃើញ៧ផ្នែក។ រួចហើយ មានការបញ្ជាក់ថែមទៀតថា នៅលើផ្នែកនីមួយៗដំបូងជនជាប់ចោទនឹងត្រូវបានសួរសំណួរបន្ទាប់មកដើមបណ្ដឹងរដ្ឋប្បវេណីដែលពាក់ព័ន្ធរួចហើយសាក្សី បន្ទាប់មកអ្នកជំនាញ ទៅតាមផ្នែកនីមួយៗ។ ពេលនេះ លោកប្រធានជាទីគោរព

---

[40] ឯកសារ E26 ។

[41] *សេចក្ដីណែនាំស្ដីពីកម្មវិធីជំនុំជម្រះ*, ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៩, កថាខណ្ឌ៩(១)។

ដើមបណ្តឹងរដ្ឋប្បវេណីភាគច្រើនដែលមិនមានអ្វីត្រូវនិយាយអំពីផ្នែកណាមួយក្នុងចំណោមផ្នែកទាំងនោះ ... សម្រាប់ក្រុមយើងខ្ញុំ នឹងមកនិយាយនៅ ចំពោះមុខតុលាការ រីឯមូលហេតុវិញ គឺថាពួកគេភាគច្រើនគឺជាសាច់ញាតិរបស់ប្រជាជន ដែលត្រូវគេឃុំខ្លួននៅមន្ទីរ ស-២១។ ដូច្នេះ ពួកគេគ្មានអ្វីត្រូវនិយាយអំពីម-១៣ មន្ទីរ ស-២១ មន្ទីរជើងឯក ឬអំពីចរិតលក្ខណៈរបស់ជនត្រូវចោទនោះទេ។ ហេតុនេះ យើងខ្ញុំនឹងថ្លែងអំណរគុណខ្លាំងណាស់ ប្រសិនបើលោកប្រធានអាចបំភ្លឺអំពីបញ្ហានេះដល់យើងខ្ញុំ និង និយាយប្រាប់យើងខ្ញុំពីពេលវេលាដែលលោកប្រធានមានបំណងកោះអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណី [...]"។

២៣. អង្គជំនុំជម្រះបានឆ្លើយតបទៅនឹងសំណើសុំការបំភ្លឺនេះ និងបានលើកឡើងថា "ពាក់ព័ន្ធនឹងការស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅពេលកាត់ទោស អង្គជំនុំជម្រះសាលាដំបូង នឹងបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីទាំងនោះដែលបានដឹងពីអង្គហេតុ ច្បាស់លាស់នៅពេលដែលអង្គជំនុំជម្រះបំពេញការងារពាក់ព័ន្ធនឹងអង្គហេតុទាំងនេះ។ ដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀតទាំងអស់ នឹងត្រូវបានស្តាប់យកចម្លើយរហូតដល់ចុងបញ្ចប់កិច្ចដំណើរការនីតិវិធី"[42]។ចម្លើយនេះបញ្ជាក់ថា ដើមបណ្តឹងរដ្ឋប្បវេណីដែលមកដល់ទីបញ្ចប់ នឹងមិនត្រូវបានវិនិច្ឆ័យពាក់ព័ន្ធនឹង"ផ្នែក" ភស្តុតាងដែលរៀបចំដោយអង្គជំនុំជម្រះសាលាដំបូង ឬអំពើជាក់លាក់ និងការប្រព្រឹត្តរបស់ជនត្រូវចោទ ឬពិរុទ្ធភាពរបស់គាត់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មនៅក្នុងការចោទប្រកាន់នោះទេ។ ដូចគ្នាដែរ ដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះនឹងជូនដំណឹងដល់អង្គជំនុំជម្រះអំពីភាពឈឺចាប់របស់ខ្លួន និងសមាជិកក្រុមគ្រួសាររបស់ខ្លួនដែលកើតចេញមកពីការប្រព្រឹត្តរបស់ជនត្រូវចោទរីឯលទ្ធផលនៃហេតុការណ៍ពាក់ព័ន្ធបានកើតមានឡើងប៉ះពាល់លើជីវិតរបស់ពួកគេ។

២៤. ឧទាហរណ៍ អំពី D25/4 ដែលជាដើមបណ្តឹងរដ្ឋប្បវេណី ក្រុម១។ នាងនឹងជម្រាបដល់អង្គជំនុំជម្រះអំពីឪពុករបស់នាង
ដែលត្រូវបានគេយកទៅបាត់បីឬបួនខែមុនពេលនាងចាប់កើតមក។ គាត់ត្រូវគេនាំទៅទួលស្លែងហើយស្លាប់នៅទីនោះ។ ចាប់តាំងពីពេលនោះមកម្តាយរបស់នាងមានការបាក់ស្បាតយ៉ាងខ្លាំងរហូតដល់កម្រិតមួយដែលគាត់ខ្លួនឯងផ្ទាល់ មិនអាចមកចូលរួមក្នុង

---

[42] ប្រតិចារឹក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០០៩, ទំព័រ៤។

ដំណើរការនីតិវិធីក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីបាន។ D25/4 នឹងផ្តល់សក្ខីកម្មអំពីទំហំដែលជីវិតរបស់នាងនិងជីវិតម្តាយរបស់នាងបានរងនូវផលប៉ះពាល់ពីការស្លាប់របស់ឪពុកនាងនៅទួលស្លែង។ សក្ខីកម្មនេះមិនពាក់ព័ន្ធនឹងពិរុទ្ធភាព របស់ជនត្រូវចោទនោះទេ។ វានឹងមិនត្រូវបានប្រើប្រាស់ធ្វើជាភស្តុតាងដើម្បីគាំទ្រដល់ការពិចារណានៅក្នុងការចោទប្រកាន់នោះទេហើយវាក៏នឹងមិនត្រូវបានពិចារណានៅក្នុងកិច្ចពិភាក្សាដេញដោលរបស់អង្គជំនុំជម្រះទៅលើបញ្ហាថាតើធាតុផ្សំនៃបទល្មើសត្រូវបានបំពេញដែរឬទេនោះ។ សក្ខីកម្មនេះ គឺពាក់ព័ន្ធផ្ទាល់ទៅនឹងការផ្តន្ទាទោសដែលផ្ទុយពីពិរុទ្ធភាពរបស់ជនត្រូវចោទ។

២៥. ការអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗ ឱ្យនិយាយប្រាប់អំពីរឿងរ៉ាវបែបនេះដែលពាក់ព័ន្ធផ្ទាល់ទៅនឹងការផ្តន្ទាទោសជនត្រូវចោទនោះ នឹងមិនទំនងទាល់តែសោះនៅពេលដែលមានការរារាំងសហមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីមិនឱ្យធ្វើសេចក្តីសន្និដ្ឋាន ដោយផ្អែកលើសក្ខីកម្មដែលពាក់ព័ន្ធនេះ។ វានឹងមានន័យថាសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីកំពុងបំពេញការងារជាប្រព័ន្ធមួយដែលពួកគេត្រូវបានអនុញ្ញាតឱ្យកោះអញ្ជើញកូនក្តីឱ្យផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការ ប៉ុន្តែបែរជាមិនអាចធ្វើសេចក្តីសន្និដ្ឋានណាមួយពាក់ព័ន្ធនឹងសក្ខីកម្មរបស់កូនក្តីទាំងនេះទៅវិញ។ លទ្ធផលដែលមិនទំនងនេះ មិនអាចជាលទ្ធផលដែលត្រូវការដោយអង្គជំនុំជម្រះនោះទេ ហើយថែមទាំងបំផ្លាញដល់ជំហររបស់សហមេធាវីការពារក្តីទៅលើបញ្ហានេះទៀតផង។

## ឃ. កំហុសនៅក្នុងគោលជំហររបស់សហមេធាវីការពារក្តី

២៦. ការពិនិត្យលើទឡ្ហីករណ៍របស់សហមេធាវីការពារក្តីពាក់ព័ន្ធនឹងមូលហេតុដែលដើមបណ្តឹងរដ្ឋប្បវេណី "ពុំមានតួនាទីអ្វីដើម្បីបំពេញ" នៅក្នុងការផ្តន្ទាទោសជនត្រូវចោទនោះ បានបង្ហាញឱ្យដឹងថា សហមេធាវីការពារក្តីមិនបានលើកឡើងនូវចំណុចនេះដោយមានការពិនិត្យពិច័យនោះទេ។ សហមេធាវីការពារក្តីបានអះអាងថា ជំហររបស់ខ្លួនដែលថាដើមបណ្តឹងរដ្ឋប្បវេណីមិនអាចធ្វើសេចក្តីសន្និដ្ឋានអំពីការផ្តន្ទាទោស *"កើតចេញមកពីការ*

*វិភាគលើបទបញ្ញត្តិដែលពាក់ព័ន្ធរបស់វិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ*"[43]។ វាមិនមែនដូច្នេះទេ។

២៧. ទីមួយ សហមេធាវីការពារក្តីផ្អែកលើវិធាន ២៣ នៃវិធានផ្ទៃក្នុង ដើម្បីតវ៉ាថា " ដើមបណ្តឹងរដ្ឋប្បវេណីអាចដាក់បានតែបណ្តឹងរដ្ឋប្បវេណីប៉ុណ្ណោះ"[44]។ ទឡ្ហីករណ៍នេះមិនត្រូវយកទៅពិចារណាទេ។ វាច្បាស់លាស់ណាស់ថា ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណើរការនីតិវិធីទាំងនេះ មិនត្រូវបានហាមឃាត់មិនឲ្យដាក់បណ្តឹងរដ្ឋប្បវេណីនោះទេ។ វិធាន ២៣(១)(ក) នៃវិធានផ្ទៃក្នុង បានចែងយ៉ាងច្បាស់ថា ដើមបណ្តឹងរដ្ឋប្បវេណីអាច "*ចូលរួមនៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ*"។ វិធាន ២៣(៦)(ក) នៃវិធានផ្ទៃក្នុង បានចែងថា "*នៅពេលដែលតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះក្លាយជាភាគីមួយនៃដំណើរការនីតិវិធីព្រហ្មទណ្ឌ*"[45]។ ដូចនេះ សហមេធាវីការពារក្តីផ្អែកលើវិធាន៤៩ នៃវិធានផ្ទៃក្នុងដើម្បីតវ៉ាថា "*ការចោទប្រកាន់អំពីបទល្មើសអាចត្រូវបានផ្តើមគំនិតដោយសហព្រះរាជអាជ្ញាតែប៉ុណ្ណោះ*"។ វាច្បាស់ណាស់ថា ព្រះរាជអាជ្ញាទទួលខុសត្រូវចំពោះការផ្តើមគំនិតចោទប្រកាន់ ដោយគ្មានអ្វីកម្រិតអំពីលទ្ធភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលការអនុញ្ញាតទាំងនោះ ក្នុងការចូលរួមនៅក្នុងដំណើរការនីតិវិធីនោះទេ។ យោងតាមចំណុចនេះ ទឡ្ហីករណ៍ដែលត្រូវបានធ្វើដោយយោងតាម វិធាន ៤៩ នៃវិធានផ្ទៃក្នុងនេះ ត្រូវបានគេយល់ខុសហើយ។

២៨. ទីពីរ សហមេធាវីការពារក្តីផ្អែកលើវិធាន ៨៧(១) នៃវិធានផ្ទៃក្នុង ដែលបានចែងថា "*សហព្រះរាជអាជ្ញាមានបន្ទុកបញ្ជាក់ពីពិរុទ្ធភាពរបស់ជនត្រូវចោទ*"[46]។ ចំណុចនេះមិនត្រូវបានជំទាស់ទេ។ របៀបដែលប្រការនេះពាក់ព័ន្ធទៅនឹងសិទ្ធិរបស់ភាគីរដ្ឋប្បវេណីក្នុងការដាក់សេចក្តីសន្និដ្ឋានអំពីការផ្តន្ទាទោសដែលជាបញ្ហាដាច់ដោយឡែកពីបញ្ហាពិរុទ្ធភាពនោះគឺពុំមានលក្ខណៈច្បាស់លាស់ឡើយ។

---

[43] ចម្លើយតបរបស់ក្រុមមេធាវីការពារ, កថាខណ្ឌ ១១។

[44] ចម្លើយតបរបស់ក្រុមមេធាវីការពារ, កថាខណ្ឌ ១១(i)។

[45] គូសបញ្ជាក់បន្ថែម។

[46] ចម្លើយតបរបស់ក្រុមមេធាវីការពារ, កថាខណ្ឌ១១ (ii)។

២៩. បន្ទាប់មកទៀត សហមេធាវីការពារក្តីបានផ្អែកលើវិធាន ៩៤(១) នៃវិធានផ្ទៃក្នុង និងបានតវ៉ាថា *"មានតែសហព្រះរាជអាជ្ញាប៉ុណ្ណោះដែលអាចធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល"* និងថា *"ចំណុចនេះរួមបញ្ចូលទាំងសិទ្ធិស្នើសុំឲ្យមានការផ្តន្ទាទោសជាក់លាក់និងកំណត់រយៈពេលជាក់លាក់"*[47]។ វាជាការពិបាកណាស់ដើម្បីយល់អំពី ថាតើសហមេធាវីការពារក្តីអាចលើកទឡ្ហីករណ៍នេះដោយរបៀបណា។ វិធាន ៩៤(១) បានចែងដូចខាងក្រោម៖

វិធាន ៩៤៖ សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល

១. ក្រោយពេលពិនិត្យលើភស្តុតាងទាំងអស់រួចហើយ ប្រធានអង្គជំនុំជម្រះឲ្យជនដូចខាងក្រោមនេះ ធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលជាបន្តបន្ទាប់គ្នា

ក-ដើមបណ្តឹងរដ្ឋប្បវេណី

ខ-សហព្រះរាជអាជ្ញាដើម្បីធ្វើការសន្និដ្ឋានប្តឹងសុំដោយផ្ទាល់មាត់ដែលខ្លួនយល់ថាសមស្របទៅនឹងប្រយោជន៍ល្អនៃយុត្តិធម៌។

គ-មេធាវីរបស់ជនជាប់ចោទ។

ឃ-ជនជាប់ចោទ។

៣០. ហេតុនេះដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ។ សហមេធាវីអាចតវ៉ាថា មានតែសហព្រះរាជអាជ្ញាប៉ុណ្ណោះដែលអាចសន្និដ្ឋានអំពីការផ្តន្ទាទោសដោយសារតែសេចក្តីសន្និដ្ឋានដែលបានបន្ថែមនៅក្នុងវិធាន ៩៤(១)(ខ) នៃវិធានផ្ទៃក្នុងពោលគឺ"ដើម្បីធ្វើការសន្និដ្ឋានប្តឹងសុំដោយផ្ទាល់មាត់ដែលខ្លួនយើងយល់ថាសមស្របទៅនឹងប្រយោជន៍ល្អនៃយុត្តិធម៌"។ ប្រសិនបើនេះជាមូលដ្ឋាននៃទឡ្ហីករណ៍របស់សហមេធាវីការពារក្តីនោះគួរកត់សម្គាល់ថាវាក៏ជាការរារាំងជនត្រូវចោទមិនឲ្យធ្វើសេចក្តីសន្និដ្ឋានអំពីការផ្តន្ទាទោសផងដែរ។ ចំណុចនេះមិនមែនជាអ្វីដែលសហមេធាវីការពារក្តីមានចេតនាសន្និដ្ឋាននោះទេ។ ទោះជាយ៉ាងណាក៏ដោយទឡ្ហីករណ៍របស់សហមេធាវីការពារក្តី

[47] ចម្លើយតបរបស់ក្រុមមេធាវីការពារ, កថាខណ្ឌ ១១ (iii)។

មិនមានប្រយោជន៍នោះទេ នៅពេលដែលមិនមាន ការចែងណាមួយនៅក្នុងវិធាន ៩៤(១) នៃវិធានផ្ទៃក្នុង ដែលកម្រិតអំពីខ្លឹមសារនៃសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ដើមបណ្តឹងរដ្ឋប្បវេណីទេនោះ។

៣១. ដូចនេះ សហមេធាវីការពារក្តីផ្អែកលើវិធាន ១០៥(១) នៃវិធានផ្ទៃក្នុង ដើម្បីតវ៉ាថា "ដើមបណ្តឹងរដ្ឋប្បវេណី អាចធ្វើបណ្តឹងសារទុក្ខបាន តែចំពោះផលប្រយោជន៍រដ្ឋប្បវេណីរបស់ខ្លួនប៉ុណ្ណោះនិងបានតែក្នុងករណីដែលមានសារទុក្ខរបស់សហព្រះរាជអាជ្ញានៅក្នុងរឿងនោះតែប៉ុណ្ណោះ"[48]។ វិធាន ១០៥(១) មិនគាំទ្រសហមេធាវីការពារក្តីនោះទេ។ វាចែងអំពីភាពអាចទទួលយកបាននៃបណ្តឹងសារទុក្ខ និងប្រាកដជាមិនបានហាមឃាត់ដើមបណ្តឹងរដ្ឋប្បវេណីមិនឱ្យធ្វើសេចក្តីសន្និដ្ឋានពាក់ព័ន្ធនឹងការផ្តន្ទាទោសនាពេលដំបូងឡើយ។

៣២. ដូចនេះ សហមេធាវីការពារក្តីមានបំណងយោងតាមការប្រតិបត្តិបែបបារាំងដើម្បីគាំទ្រគោលជំហររបស់ខ្លួន ប៉ុន្តែបានលើកយកតែសេចក្តីសន្និដ្ឋានផ្ទាល់ខ្លួនរបស់សហមេធាវីការពារក្តីនៅក្នុងពេលជជែកតវ៉ាតែប៉ុណ្ណោះ[49]។ ត្រង់ចំណុចនេះ CPG-1 និង CPG-2 កត់សម្គាល់ឃើញអំពីនិន្នាការនៅក្នុងកិច្ចដំណើរការនីតិវិធីទាំងនេះ ដែលផ្អែកលើការប្រតិបត្តិក្នុងប្រទេសដោយមិនផ្តល់ការគាំទ្រផ្នែកច្បាប់ឬផ្នែកយុត្តិសាស្ត្រនោះទេ។ ត្រូវមានការពិនិត្យឡើងវិញដ៏ត្រឹមត្រូវត្រូវមួយ។ នៅក្នុងយុត្តាធិការច្បាប់ស៊ីវិលជនរងគ្រោះ មានសិទ្ធិក្នុងការចូលរួមដ៏ទូលំទូលាយនៅគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធីរួមទាំងនៅដំណាក់កាលផ្តន្ទាទោសផងដែរ[50]។ ដោយសារតែសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលមិនត្រូវបានកម្រិតលើក្របខណ្ឌឬលើខ្លឹមសាររបស់វាទេនោះ សេចក្តីសន្និដ្ឋានអំពីការផ្តន្ទាទោសត្រូវបានអនុញ្ញាត។ ឧទាហរណ៍: នៅប្រទេសបារាំង មិនមានបញ្ញត្តិណាមួយនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ដែលហាមឃាត់ដើមបណ្តឹងរដ្ឋប្បវេណីមិនឱ្យធ្វើសេចក្តីសន្និដ្ឋានអំពីការផ្តន្ទាទោសនោះទេ[51]។ នៅប្រទេសស្វីស ប្រទេសអេស្ប៉ាញ

---

[48] ចម្លើយតបរបស់ក្រុមមេធាវីការពារ, កថាខណ្ឌ១១ (iv)។

[49] ចម្លើយតបរបស់ក្រុមមេធាវីការពារ, កថាខណ្ឌ១៣។

[50] *ឧទហរណ៍ សូមមើល,* ក្រមនីតិវិធីព្រហ្មទណ្ឌអាល្លឺម៉ង់, § 397, កថាខណ្ឌ១។

[51] Code de Procédure Pénale, Article 346: 'Une fois l'instruction à l'audience terminée la partie civile ou son avocat est entendu. Le ministère public prend ses réquisitions. L'accusé et son avocat présentent leur défense. **La réplique est permise à la partie civile** et au ministère public, mais l'accusé ou son avocat auront toujours la parole les derniers.' (Emphasis added).

ប្រទេសស៊ុយអែត ប្រទេសប៉ូឡូញ ប្រទេសទួរគី និងប្រទេសហុងគ្រី ជនរងគ្រោះក៏មានសិទ្ធិដាក់បណ្តឹងសារទុក្ខប្រឆាំងនឹងការដាក់ទោសផងដែរ[52]។

៣៣. ជាសំខាន់ ទោះបីជានៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌនៃច្បាប់ Common Law ដែលមិនបានចែងនូវបញ្ញត្តិបែបនេះ ចំពោះការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះក៏ដោយ ក៏យុត្តាធិការមួយចំនួនធំបានចែងច្បាប់សម្រាប់ការចូលរួមរបស់ជនរងគ្រោះ នៅក្នុងដំណាក់កាលផ្តន្ទាទោស។ នៅចក្រភពអង់គ្លេស[53] ប្រទេសអូស្ត្រាលី[54] ប្រទេសកាណាដា[55] ប្រទេសណូវែលហ្សេឡង់[56] និង សហរដ្ឋអាមេរិក[57] ជនរងគ្រោះអាចចូលរួម

---

[52] នៅអេស្ប៉ាញ ក្រូអាត និងស៊ុយអែត per se ក្នុងតួនាទីពួកគេជារដ្ឋអាជ្ញាបន្ថែម នៅស្វីស ប៉ូឡូញ ស៊ុយអែត និងទួគី និងជារដ្ឋអាជ្ញាឯកជន នៅស្វីស អេស្ប៉ាញ ហុងហ្គារី ក្រូអាត ប៉ូឡូញ និងស៊ុយអែត ; Marianne Wade, Christopher Lewis, Bruno Aubusson de Cavarlay, *Well-informed? Well Represented? Well Nigh Powerless? Victims and Prosecutorial Decision making*, European Journal on Criminal Policy and Research 2008, ទំព័រ ២៥០-២៥៧។

[53] The Home Office បានបង្ហាញឱ្យស្គាល់អំពី Victim Personal Statement Scheme ("VPS Scheme") ក្នុងខែតុលា ឆ្នាំ២០០១ ក្រោមការគាំទ្ររបស់ Victim's Charter (១៩៩០)។ ក្រោម គ្រោងការណ៍នេះ VPS ត្រូវគេទាមទារឱ្យយកទៅពិចារណា ក្នុងដំណាក់កាលនីមួយនៃដំណើរការ ព្រហ្មទណ្ឌរួមមានការផ្តន្ទាទោស (Home Office Communication Directorate, "Making a Victim Personal Statement" ខែសីហា ឆ្នាំ២០០១;

[54] រដ្ឋទាំងអស់ និងទឹកដីនៅអូស្ត្រាលី បានអនុម័តបទបញ្ញត្តិដែលតម្រូវឱ្យតុលាការគិតគូរដល់ជនរងគ្រោះក្នុងតំណាក់កាលផ្តន្ទាទោស ជាទូទៅតាមរយៈការផ្តល់ឱ្យនូវសេចក្តីថ្លែងការណ៍អំពីផលប៉ះពាល់ ដល់ជនរងគ្រោះ (មើលឧក្រិដ្ឋកម្ម (នីតិវិធីផ្តន្ទាទោស) *Act 1999 (NSW)* ss26 - 30A; *Sentencing Act (NT)* ss 106A, 106B; Criminal Office Victims Act 1999 *(Qld)* s 14; *Criminal Law (Sentencing) Act 1998 (SA)* s7A; *Victims of Crime Act (SA)* s 10; *Sentencing Act 1997 (Tas)* s 81 A; *Sentencing Act (Vic)* ss 95A -95F; *Sentencing Act (1995) (WA)* ss24-26; *Crimes (Sentencing) Act 2005 (ACT)* ss47-53)។

[55] ការកែទម្រង់ដ៏សំខាន់បានកើតមាននៅក្នុងច្បាប់ប្រទេសកម្ពុជា ដើម្បីអនុញ្ញាតឱ្យជនរងគ្រោះធ្វើការបញ្ជាក់ដោយផ្ទាល់មាត់អំពីផលប៉ះពាល់របស់ជនរងគ្រោះ ស្ថិតនៅក្រោមក្រមព្រហ្មទណ្ឌឆ្នាំ១៩៨៨ ដូចដែលបានធ្វើវិសោធនកម្ម ហើយជនរងគ្រោះត្រូវបានផ្តល់នូវតួនាទីជាផ្លូវការនៅពេលសវនាការផ្តន្ទាទោស និងដោះលែងដោយមានលក្ខខណ្ឌ (Verdun-Jones, Simon N. ។ Tijerino, Adanira, "ការចូលរួមរបស់ជនរងគ្រោះនៅក្នុងដំណើរការពិភាក្សាអំពីចម្លើយទទួលពិរុទ្ធភាព : An Idea Whose Time Has Come" (2005) 50 Criminal Law Quarterly ទំព័រ ១៩២)។

[56] Victims' Right Act 2002 No. 39 (នៅថ្ងៃទី១ ខែតុលា ឆ្នាំ២០០៨), s 17(1)។

នៅក្នុងដំណាក់កាលផ្តន្ទាទោស តាមរយៈការផ្តល់សក្ខីកម្មផ្ទាល់មាត់ ឬតាមរយៈការរៀបចំសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរអំពីផលប៉ះពាល់។ នេះជាការទទួលស្គាល់យ៉ាងប្រាកដដែលថា ជនរងគ្រោះត្រូវបានផ្តល់តួនាទីពិសេសតែមួយគត់ឱ្យជួយដល់តុលាការទៅលើបញ្ហានៃការផ្តន្ទាទោសទោះបីជានៅក្នុងយុត្តាធិការនានាដែលមិនអនុញ្ញាតឱ្យមានការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌក៏ដោយ។

៣៤. សូម ងាកទៅគិតអំពីទឡ្ហីករណ៍របស់សហមេធាវីការពារក្តីដែលនៅសេសសល់ វិញម្តង។ សេចក្តីសន្និដ្ឋានរបស់សហមេធាវីការពារក្តីដែលថាការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីអំពីបញ្ហាផ្តន្ទាទោសនឹងធ្វើឱ្យមានការពន្យាពេលសវនាការ និងរំលោភ លើសិទ្ធិរបស់គាត់ក្នុងការទទួលបានការកាត់ទោសក្នុងរយៈពេលមួយសមស្របនោះ[58]ក៏គ្មានតម្លៃនោះដែរ។ ដើមបណ្តឹងរដ្ឋប្បវេណីបានរង់ចាំអស់រយៈពេលជាង ៣០ឆ្នាំមកហើយ ដើម្បីពន្យល់ដល់តុលាការអំពីថាតើអំពើរបស់ជនត្រូវចោទបានជីវិតបែកបាក់និរាសព្រាត់ប្រាស់យ៉ាងដូចម្តេចខ្លះ។ ការស្តាប់សក្ខីកម្មដែលមានពេលកំណត់របស់ដើមបណ្តឹងរដ្ឋប្បវេណី និង ការអនុញ្ញាតឱ្យសហមេធាវីរបស់គាត់ធ្វើសេចក្តីសន្និដ្ឋាន អំពីចំណុចសំខាន់ៗរបស់ខ្លួន នឹងមិនរំលោភលើសិទ្ធិក្នុងការទទួលបានការកាត់សេចក្តីឆាប់រហ័សនោះទេ។

៣៥. សហមេធាវីការពារក្តីក៏មានបំណងតវ៉ាដែរថាការស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីអំពីការផ្តន្ទាទោសនោះនឹងក្លាយ "ជាការរំលោភលើសមភាពនៃមធ្យោបាយក្នុងការតទល់ក្តីរវាងភាគី ពីព្រោះសហមេធាវីការពារក្តីនឹងត្រូវឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានស្តីពីការផ្តន្ទាទោស ដូចដែលត្រូវបានធ្វើឡើងដោយការិយាល័យសហព្រះរាជអាជ្ញាព្រមទាំងក្រុមសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលដើរតួដូចជាសហព្រះរាជអាជ្ញា"

---

[57] The Attorney General Guidelines for Victim and Witness Assistance (2005) ចែងថា ជនរងគ្រោះ ដោយអំពើឧក្រិដ្ឋមានសិទ្ធិ ស្ថិតក្រោម U.S.C. § 3771(a) "ផ្តល់ចម្លើយសមហេតុផល នៅពេលមានដំណើរការនីតិវិធីជាសាធារណៈ នៅក្នុងសាលាដំបូង ពាក់ព័ន្ធទៅនឹង ការដោះលែង ការឆ្លើយទទួលពិរុទ្ធភាព ការផ្តន្ទាទោស និងដំណើរការនីតិវិធីដោះលែងដោយមានលក្ខខណ្ឌ"។

[58] ចម្លើយតបរបស់ក្រុមមេធាវីការពារ, កថាខណ្ឌ១៧។

[59]។ ទឡ្ហីករណ៍នេះមិនត្រូវយកទៅធ្វើការពិចារណាដោយអង្គជំនុំជម្រះនោះទេ។ ចំនួនភាគីដែលភាគីម្ខាងទៀតជ្រើសរើសធ្វើការឆ្លើយតបចំពោះខ្លួននោះ គឺមិនពាក់ព័ន្ធទៅនឹងសមភាពនៃមធ្យោបាយក្នុងការតទល់ក្តីរវាងនោះទេ។ នៅក្នុងសំណុំរឿងលេខ ០០២ "សមភាពនៃមធ្យោបាយក្នុងការតទល់ក្តី" នឹងមិនត្រូវបានរំលោភបំពាននោះទេ ពីព្រោះសហព្រះរាជអាជ្ញាត្រូវបានតម្រូវឱ្យឆ្លើយតបទៅនឹងទឡ្ហីករណ៍របស់ជនត្រូវចោទទាំងបួនរូបដែលផ្ទុយទៅនឹងជនត្រូវចោទមួយរូបនៅក្នុងការកាត់សេចក្តីបច្ចុប្បន្ននេះ ។ ដូចទឡ្ហីករណ៍ទាំងអស់ដែលត្រូវបានពិនិត្យខាងលើនេះទឡ្ហីករណ៍របស់សហមេធាវីការពារក្តីនេះ គ្មានមូលដ្ឋានច្បាស់លាស់ទេ។ សហមេធាវីការពារក្តីពុំបានរកឃើញថា មានការគាំទ្រទាំងនៅក្នុងវិធានផ្ទៃក្នុង ក៏ដូចជានៅក្នុងការប្រតិបត្តិក្នុងប្រទេស ឬតាមរយៈការផ្អែកលើសិទ្ធិក្នុងការទទួលបានសវនាការយុត្តិធម៌ចំពោះជំហររបស់ខ្លួន ដែលថាដើមបណ្តឹងរដ្ឋប្បវេណី គួរតែត្រូវបានរារាំងមិនឱ្យឡើងផ្តល់ចម្លើយស្តីពីបញ្ហាផ្តន្ទាទោសនោះ។

## ខ. ការរួមចំណែកដ៏ពិសេសរបស់ដើមបណ្តឹងរដ្ឋប្បវេណី

៣៦. ការផ្តន្ទាទោសជនត្រូវចោទម្នាក់គឺជាដំណើរការមួយដ៏ស្មុគស្មាញ។ ទិដ្ឋភាពផ្សេងគ្នាជាច្រើនតម្រូវឱ្យមានការពិចារណាមុនពេលចេញសេចក្តីសម្រេចក្នុងការផ្តន្ទាទោស ដែលឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវ និងគ្រប់គ្រាន់ដល់ការប្រព្រឹត្តអំពើឧក្រិដ្ឋរបស់ជនជាប់ចោទ។ អង្គជំនុំជម្រះត្រូវកំណត់ការថ្លឹងថ្លែងដើម្បីឱ្យត្រូវគ្នាទៅនឹង (ប្រសិនបើមាន) ស្ថានសម្រាលទោសនិងស្ថានដាក់ទម្ងន់ទោសជាច្រើន ហើយត្រូវពិចារណាទៅលើភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ។ ផលប៉ះពាល់នៃការឆ្លើយព្រមទទួលកំហុសណាមួយត្រូវបានយកមកពិចារណា។ តម្លៃនៃការសំដែងអំពីវិប្បដិសារី ឬការសុំអភ័យទោស ត្រូវបានយកមកធ្វើការសម្រេច។ អង្គជំនុំជម្រះត្រូវពិចារណាថាតើ ការផ្តន្ទាទោសត្រួត អាចទទួលយកបាន ឬយ៉ាងណា។ ត្រូវមានការពិចារណាទៅលើថាតើ ទោសមួយត្រូវបានគេធ្វើការសម្រេច ឬថាតើការផ្តន្ទាទោសមួយក្នុងចំណោមការផ្តន្ទាទោសជាច្រើនតម្រូវឱ្យមានទោសផ្សេងពី គ្នាឬយ៉ាងណា ហើយថាតើការផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មផ្សេងគ្នាត្រូវបានទទួលនៅពេលដំណាល

[59] ចម្លើយតបរបស់សហមេធាវីការពារក្តី កថាខណ្ឌ ១៦។

គ្នាឬយ៉ាងណា។ សេចក្តីសម្រេចក៏ត្រូវតែធ្វើផងដែរចំពោះវិសាលភាពដែល ដែលក្នុងនោះនីតិវិធីក្នុងការផ្តន្ទាទោសនៅក្នុងយុត្តាធិការជាតិគួរតែត្រូវបានពិចារណា។

៣៧. ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានដាក់ឲ្យតួនាទីយ៉ាងពិសេសដើម្បីជួយដល់អង្គជំនុំជម្រះក្នុងការធ្វើសេចក្តីសម្រេចទៅលើបញ្ហាជាច្រើនទាំងនេះ។ ដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើការវាយតម្លៃដល់អង្គជំនុំជម្រះ អំពីផលប៉ះពាល់ជាក់ស្តែងនៃឧក្រិដ្ឋកម្មរបស់ជនត្រូវចោទទៅលើពួកគេ គ្រួសាររបស់ពួកគេ និងជនរងគ្រោះដទៃទៀតដែលគេស្គាល់។ ដើមបណ្តឹងរដ្ឋប្បវេណីអាចដាក់ការសន្និដ្ឋានអំពីឥទ្ធិពលនៃការសំដែងពីវិប្បដិសារី ឬក៏ការសុំអភ័យទោសណាមួយ ដែលពិតជាបានធ្វើឡើងដោយជនជាប់ចោទ។ ដើមបណ្តឹងរដ្ឋប្បវេណីក៏ត្រូវបានដាក់ឲ្យស្ថិតនៅក្នុងតួនាទីយ៉ាងល្អផងដែរ ដើម្បីលើកយកគោលសំខាន់ៗអំពីអ្វីដែលជាសេចក្តីអះអាងមិនពិត ឬពន្លើស ដែលបានធ្វើឡើងដោយជនជាប់ចោទនៅក្នុងការសម្រាលទោស។ ដូច្នេះ ជំហររបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ និងក្រុម២ គឺថាការផ្តន្ទាទោសដែលត្រូវបានសម្រេចផ្អែកយ៉ាងត្រឹមត្រូវទៅលើកត្តាទាំងនេះ នឹងមានលក្ខណៈប្រាកដត្រឹមត្រូវនិងមានអត្ថន័យជាងសេចក្តីសម្រេចផ្តន្ទាទោសដែលធ្វើឡើងដោយទាញយកគុណប្រយោជន៍នៃសេចក្តីសន្និដ្ឋានបែបនេះ។ សូមសន្និដ្ឋានថា នឹងមិនមានការប៉ះពាល់ដល់សហមេធាវីការពារក្តីឡើយក្នុងការយល់ព្រមទៅនឹងសំណើនេះ។ សំឡេងដែលគេស្តាប់ឮពីដើមបណ្តឹងរដ្ឋប្បវេណី គឺមិនលុបលើសំឡេងរបស់ជនជាប់ចោទឡើយ។ មិនមានការប៉ះពាល់គួរឲ្យកត់សំគាល់កើតមានចំពោះសហមេធាវីការពារក្តី ឬក៏ភាគីដទៃទៀតណាមួយឡើយ ប្រសិនបើសំណើនេះត្រូវបានយល់ព្រម។ លើសពីនេះទៀត ដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ និងក្រុម២ មានការជឿជាក់ថា ជាចៅក្រមប្រកបដោយវិជ្ជាជីវៈអង្គជំនុំជម្រះសាលាដំបូងមានលទ្ធភាពពេញលេញក្នុងការផ្តល់នូវការថ្លឹងថ្លែងឲ្យបានសមរម្យចំពោះសេចក្តីសន្និដ្ឋានណាដែលត្រូវបានធ្វើឡើយដោយភាគីណាមួយស្តីអំពីបញ្ហានេះ។ សរុបសេចក្តីមកសូមដាក់ជូនសេចក្តីសន្និដ្ឋានដោយសេចក្តីគោរពថាគុណភាពនៃការធ្វើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើបញ្ហានេះ នឹងមានលក្ខណៈប្រសើរថែមទៀតតាមរយៈដោយផ្តល់នូវការយល់ព្រមទៅនឹងសំណើនេះ។

៣៨. ការពិនិត្យឡើងវិញអំពីការអនុវត្តការផ្តន្ទាទោសនៅតុលាការ ICTR និងតុលាការ ICTY ផ្តល់នូវការគាំទ្រដល់ជំហររបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ និងក្រុម២។ ឧទាហរណ៍

បញ្ហានៃផលប៉ះពាល់អំពីចម្លើយទទួលពិរុទ្ធភាពអំពីទោសរបស់ជនត្រូវចោទ ដែលជាបញ្ហាទាក់ទិនទៅនឹងដំណើរការនីតិវិធីនាពេលថ្មីៗនេះ។ នៅក្នុងករណី Plavšić អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា ចម្លើយទទួលពិរុទ្ធភាពរបស់ជនជាប់ចោទ នឹងមាន *"ផលជាវិជ្ជមានទៅលើដំណើរការផ្សះផ្សា"* ហើយដូច្នេះអង្គជំនុំជម្រះបានយល់ ថា ចម្លើយទទួលពិរុទ្ធភាព "ជាការថ្លឹងថ្លែងដ៏មានមានសារៈសំខាន់" នៅក្នុងការធ្វើសេចក្តីសម្រេចរបស់ខ្លួនអំពីការផ្តន្ទាទោសឱ្យបានសមស្រប[60]។ ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូងរបស់ តុលាការ ICTY ត្រូវបានតម្រូវឱ្យធ្វើសេចក្តីសម្រេចរបស់ខ្លួនក្នុងលក្ខណៈបំព្រួញ ដោយមិនបានគិតពីផលប្រយោជន៍នៃការស្តាប់សេចក្តីសន្និដ្ឋានរបស់ជនរងគ្រោះផ្ទាល់ស្តីអំពីថាតើចម្លើយទទួលពិរុទ្ធភាពពិតជាមានផលជាវិជ្ជមានទៅលើតំបន់នោះឬ យ៉ាងណានោះទេ។ ទស្សនៈផ្ទុយដែលប្រកាន់យកនៅតុលាការ ICTY គឺថា ចម្លើយទទួលពិរុទ្ធភាពពិតជាមានផលអាក្រក់ដល់ជនរងគ្រោះ ដោយសារតែចម្លើយទទួលពិរុទ្ធភាពធ្វើឱ្យតុលាការមិនមានឱកាសដើម្បីបង្ហាញឱ្យបានពេញលេញអំពីភាពពេញលេញនៃការប្រព្រឹត្តរបស់ជនជាប់ចោទតាមរយៈការដាក់ការផ្តន្ទាទោស ដែលឆ្លុះបញ្ចាំងគ្រប់ គ្រាន់អំពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម និងភាពសមនឹងទទួលទោសរបស់ជនត្រូវចោទ[61]។

៣៩. អត្ថិភាពនៃទស្សនៈផ្ទុយគ្នាទាំងស្រុងទៅលើទិដ្ឋភាពសំខាន់នៃការផ្តន្ទាទោសនេះ គឺពិតណាស់ជាលទ្ធផលនៃការខ្វះខាតនៃការចូលរួមរបស់ជនរងគ្រោះនៅក្នុងដំណើរការនៃការផ្តន្ទាទោស។ នៅពេលដែលមិនមានសេចក្តីសន្និដ្ឋានរបស់ជនរងគ្រោះ អង្គជំនុំជម្រះរបស់ តុលាការ ICTY និងតុលាការ ICTR ត្រូវបានរារាំងមិនឱ្យធ្វើសេចក្តីសម្រេចទៅលើទិដ្ឋភាពសំខាន់នានានៃការផ្តន្ទាទោស ដូចជា ថាតើចម្លើយទទួលពិរុទ្ធភាពពិតជាមានផលជាវិជ្ជមានទៅលើជនរងគ្រោះ ឬទៅលើតំបន់ជាទូទៅជាងឬយ៉ាងណា។ អ.វ.ត.ក គួរតែទាញយកផលប្រយោជន៍ឱ្យបានពេញលេញក្នុងការស្វែងយល់ពីទស្សនៈរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ការចូលរួមរបស់ពួកគេនឹងសម្រួលដល់ការចេញសេចក្តីសម្រេចផ្តន្ទាទោសដោយមានភាពត្រឹមត្រូវតាមច្បាប់ និងទទួលយកបានយ៉ាងពិតប្រាកដ ហើយ

---

[60] រដ្ឋអាជ្ញា ទល់នឹង Plavšić, IT-0039&40/1-S, សាលក្រមទៅលើការផ្តន្ទាទោស ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៣ កថាខណ្ឌ៨០, ៨១។

[61] សូមអាន រដ្ឋអាជ្ញា ទល់នឹង Deronjić, IT-0261-S, សាលក្រមផ្តន្ទាទោស ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៤ យោបល់ផ្ទុយគ្នារបស់ចៅក្រម Schomburg។

ដោយមានឱកាសប្រាកដនិយមនៃការមានផលជាវិជ្ជមានទៅលើការរស់នៅរបស់ប្រជាជន ដែលតុលាការនេះត្រូវបានបង្កើតឡើងដើម្បីប្រជាជនទាំងនោះ។

## IV. សន្និដ្ឋាន

៤០. ទស្សនៈមួយលើកឡើងថា "វាគឺជាការបង្កឱ្យមានព្យសនកម្មលើកទីពីរទៅលើជនរងគ្រោះក្នុងការបដិសេធសិទ្ធិរបស់ជនរងគ្រោះមិនឱ្យបញ្ចេញយោបល់ ចំពោះការផ្តន្ទាទោសអំពីទំហំ និងលទ្ធផលនៃព្យសនកម្មលើកទីមួយ[62]"។ ស្រដៀងគ្នានេះដែរ ក្នុងការកោះហៅដើមបណ្តឹងរដ្ឋប្បវេណី ឱ្យចូលមកធ្វើការពន្យល់ដល់អង្គជំនុំជម្រះអំពីរបៀបដែលអំពើរបស់ជនជាប់ចោទបានបំផ្លាញដល់អាយុជីវិត និងក្រុមគ្រួសារ ដោយគ្រាន់តែរារាំងមិនឱ្យមេធាវីរបស់ពួកគេធ្វើសេចក្តីសន្និដ្ឋានដោយផ្អែកទៅលើសក្ខីកម្ម វានឹងជាវិធីសាស្ត្រមួយមិនមានយុត្តិកម្ម និងមិនសមហេតុផលឡើយ។ ពិតណាស់ ការផ្តន្ទាទោសជាទិដ្ឋភាពមួយនៃដំណើរការនីតិវិធី ដែលដើមបណ្តឹងរដ្ឋប្បវេណីអាច និងគួរតែចូលរួម។ តាមវិធានផ្ទៃក្នុង មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិ ក្នុងការធ្វើសេចក្តីសន្និដ្ឋានបែបនេះ ហើយពួកគេអាចជួយយ៉ាងច្រើនដល់អង្គជំនុំជម្រះក្នុងការធ្វើសេចក្តីសម្រេច។ អង្គជំនុំជម្រះសាលាដំបូងត្រូវបានអនុញ្ញាតឱ្យទាញយកផលប្រយោជន៍ក្នុងការស្តាប់សេចក្តីសន្និដ្ឋានរបស់បុគ្គលទាំងឡាយណាដែលត្រូវបានផ្តល់តួនាទីយ៉ាងពិសេសដើម្បីផ្តល់ជូនអង្គជំនុំជម្រះនូវការយល់ឃើញយ៉ាងស៊ីជម្រៅទៅក្នុងបញ្ហាទាំងឡាយដែលមានសារៈសំខាន់ក្នុងដំណើរការផ្តន្ទាទោស។ សូមដាក់ជូនដោយសេចក្តីគោរពដល់អង្គជំនុំជម្រះ សូមផ្តល់នូវការយល់ព្រមតាមសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសូមធ្វើការបំភ្លឺអំពីបញ្ហាដ៏សំខាន់នេះ។

## V. សំណើ

[62] Douglas Evan Beloof, "គំរូទីបីនៃរឿងក្តីព្រហ្មទណ្ឌៈ គំរូនៃការចូលរួមរបស់ជនរងគ្រោះ (1999) Utah Law Review ទំព័រ ៣២២។

V. **សំណើ**

៤១. សេចក្តីដូចបានជម្រាបជូនខាងលើ ដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ និងក្រុម២ សូមស្នើដោយសេចក្តីគោរពដល់អង្គជំនុំជម្រះសាលាដំបូងឲ្យ **សម្រេច** អនុញ្ញាតឲ្យសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីឡើងធ្វើសេចក្តីសន្និដ្ឋានស្តីអំពីការផ្តន្ទាទោសជនជាប់ចោទ។

សូមដាក់ជូនដោយក្តីគោរពពី
សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី(ក្រុម១ និង ក្រុម២),
ចុះហត្ថលេខានៅរាជធានីភ្នំពេញ

នាថ្ងៃទី..... ខែឧសភា ឆ្នាំ២០០៩

Karim. A.A. Khan    ទី ស្រ៊ីនណា

Alain Werner    Brianne McGonigle

ហុង គីមសួន    គង់ ពិសី

យ៉ុង ផានិត